ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍និងលក្ខខណ្ឌ សម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់ គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា

(១)~ ប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការកំណត់គោលការណ៍និងលក្ខខណ្ឌសម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា

(២)~ ឯកសារពន្យល់សម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស

បោះពុម្ពដោយអាជ្ញាធរអគ្គិសនីកម្ពុជា

ខែ កក្កដា ឆ្នាំ ២០០៧

# គោលការណ៍និងល័ក្ខខ័ណ្ឌសម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូន
# សម្រាប់គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា

## ជំពូក ១
## គោលការណ៍ទូទៅ

### គោលការណ៍ទី១. មធ្យោបាយបញ្ជូនអគ្គិសនី និងមធ្យោបាយរងបញ្ជូនអគ្គិសនី

មធ្យោបាយអគ្គិសនីដែលប្រើប្រាស់សម្រាប់ផ្ទេរអគ្គិសនីក្នុងរូបភាពដុំ និងក្នុងចម្ងាយវែងហៅថា **មធ្យោបាយបញ្ជូនអគ្គិសនី** ។ យោងតាមស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍន៍ខ្សែបណ្តាញអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាក្នុងដំណាក់កាលដំបូង មធ្យោបាយបញ្ជូនអគ្គិសនីត្រូវបានចែកជាពីរប្រភេទ គឺ : **មធ្យោបាយបញ្ជូនអគ្គិសនី** និង **មធ្យោបាយរងបញ្ជូនអគ្គិសនី** ។

ខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ រួមជាមួយអនុស្ថានីយតង់ស្យុងខ្ពស់/មធ្យម ព្រមទាំងប្រព័ន្ធត្រួតពិនិត្យ ប្រព័ន្ធការពារ ប្រព័ន្ធនាឡិកាស្ទង់ និងប្រព័ន្ធគមនាគមន៍ពាក់ព័ន្ធ ដែលប្រើប្រាស់សម្រាប់ការបញ្ជូនអគ្គិសនីត្រូវចាត់ទុកជា **មធ្យោបាយបញ្ជូនអគ្គិសនី** ។

ខ្សែបណ្តាញតង់ស្យុងមធ្យម និងមធ្យោបាយរួមផ្សំដទៃទៀត ដែលប្រើប្រាស់សម្រាប់បញ្ជូនអគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្សេងៗ ឬឱ្យអ្នកប្រើប្រាស់អគ្គិសនីដុំ ត្រូវចាត់ទុកជា **មធ្យោបាយរងបញ្ជូនអគ្គិសនី** ។

### គោលការណ៍ទី២. អាជ្ញាប័ណ្ណសម្រាប់ដំណើរការមធ្យោបាយបញ្ជូនអគ្គិសនី និងមធ្យោបាយរងបញ្ជូនអគ្គិសនី

អ្នកធ្វើសេវាកម្មបញ្ជូនអគ្គិសនីត្រូវមានអាជ្ញាប័ណ្ណបញ្ជូនអគ្គិសនីចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ អាជ្ញាប័ណ្ណបញ្ជូនអគ្គិសនីមានពីរប្រភេទ គឺ អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី និងអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស។

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីមានសិទ្ធិសាងសង់ ធ្វើជាម្ចាស់ និងដំណើរការលើមធ្យោបាយបញ្ជូនអគ្គិសនី និងមធ្យោបាយរងបញ្ជូនអគ្គិសនី នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសមានសិទ្ធិសាងសង់ ធ្វើជាម្ចាស់ និង ដំណើរការលើមធ្យោបាយបញ្ជូនអគ្គិសនី និង/ឬ លើមធ្យោបាយរងបញ្ជូនអគ្គិសនី ដែលបានកំណត់ជាក់លាក់ក្នុងអាជ្ញាប័ណ្ណ

របស់ខ្លួន ។ អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស អាចចេញឱ្យសម្រាប់ **ទ្វារចរន្តរ៉ាដ្យាល់** ក៏ដូចជា **ទ្វារចរន្តដែលស្របទិសដៅ** ជាមួយទ្វារចរន្តដទៃទៀតដែរ ។

**ទ្វារចរន្តរ៉ាដ្យាល់** គឺជាខ្សែបណ្តាញបញ្ជូនអគ្គិសនី ឬខ្សែបណ្តាញរងបញ្ជូនអគ្គិសនីទោលតែមួយគត់ ដែលអាចធ្វើការផ្ទេរអគ្គិសនីក្នុងរូបភាពធំរវាងចំណុចពីរ ។

**ទ្វារចរន្តស្របទិសដៅ** គឺជាខ្សែបណ្តាញបញ្ជូនអគ្គិសនី ឬខ្សែបណ្តាញរងបញ្ជូនអគ្គិសនីមួយក្នុងចំណោមខ្សែបណ្តាញច្រើនដែលអាចធ្វើការផ្ទេរអគ្គិសនីក្នុងរូបភាពជុំរវាងចំណុចពីរ ។

## គោលការណ៍ទី៣. ករណីលើកលែងការទាមទារអាជ្ញាប័ណ្ណបញ្ជូនសម្រាប់ការដំណើរការមធ្យោបាយបញ្ជូនអគ្គិសនីខ្លះ

ខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ដែលមានប្រវែងមិនលើសពី ៥០ គីឡូម៉ែត្រ ឬ ខ្សែបណ្តាញតង់ស្យុងមធ្យមដែលមានប្រវែងមិនលើសពី ២០ គីឡូម៉ែត្រ ដែលជាកម្មសិទ្ធិនិងដំណើរការដោយអ្នកកាន់អាជ្ញាប័ណ្ណផលិតកម្មមួយ ហើយប្រើសម្រាប់តែភ្ជាប់រោងចក្រអគ្គិសនីរបស់ខ្លួនជាមួយប្រព័ន្ធបណ្តាញបញ្ជូនមេ ត្រូវចាត់ទុកជាមធ្យោបាយតភ្ជាប់នៃរោងចក្រអគ្គិសនីនោះ ហើយអាចដំណើរការក្រោមអាជ្ញាប័ណ្ណផលិតកម្ម ដែលបានផ្តល់ឱ្យសម្រាប់រោងចក្រអគ្គិសនីនោះ ។

ខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ដែលមានប្រវែងមិនលើសពី ៣០ គីឡូម៉ែត្រ ឬ ខ្សែបណ្តាញតង់ស្យុងមធ្យមដែលមានប្រវែងមិនលើសពី ១០ គីឡូម៉ែត្រ ដែលជាកម្មសិទ្ធិនិងដំណើរការដោយអ្នកប្រើប្រាស់អគ្គិសនីធំ ឬអ្នកប្រើប្រាស់អគ្គិសនីតង់ស្យុងមធ្យមមួយ ហើយប្រើប្រាស់សម្រាប់តែដឹកនាំថាមពលអគ្គិសនីទៅឱ្យកន្លែងប្រើប្រាស់ផ្ទាល់ខ្លួននោះ ត្រូវបានចាត់ទុកជា ផ្នែកមួយនៃបរិក្ខារអគ្គិសនីរបស់អ្នកប្រើប្រាស់ ដូច្នេះមិនចាំបាច់មានអាជ្ញាប័ណ្ណសម្រាប់ដំណើរការខ្សែបណ្តាញនោះទេ ។

ខ្សែបណ្តាញតង់ស្យុងមធ្យមដែលជាកម្មសិទ្ធិរបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយមួយ ហើយស្ថិតនៅក្នុងតំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណនោះ និងខ្សែបណ្តាញតង់ស្យុងមធ្យម ដែលជាកម្មសិទ្ធិរបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយមួយ ដែលមានការអនុញ្ញាតពីអាជ្ញាធរអគ្គិសនីកម្ពុជាឱ្យសាងសង់នៅក្រៅតំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណនោះ ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណចែកចាយដែលបានផ្តល់ឱ្យ ហើយប្រើប្រាស់សម្រាប់នាំចូលប្រភពអគ្គិសនីមកផ្គត់ផ្គង់ឱ្យតំបន់ចែកចាយរបស់ខ្លួន ត្រូវចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធចែកចាយក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណចែកចាយនោះ ដូច្នេះមិនចាំបាច់មានអាជ្ញាប័ណ្ណបញ្ជូនសម្រាប់ដំណើរការខ្សែបណ្តាញនោះទេ ។

# ជំពូក ២
# គោលការណ៍សម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសសម្រាប់មធ្យោបាយបញ្ជូនអគ្គិសនី

## គោលការណ៍ទី៤. សិទ្ធិសាងសង់និងដំណើរការមធ្យោបាយបញ្ជូនណាមួយ

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ត្រូវមានសិទ្ធិមុនគេក្នុងការសាងសង់ និងដំណើរការមធ្យោបាយបញ្ជូនណាមួយដែលត្រូវការចាំបាច់ ឬដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ ក្នុងរយៈពេលមួយដែលគេត្រូវការមធ្យោបាយបញ្ជូននោះ ។ ប្រសិនបើ អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី មិនមានលទ្ធភាពទទួលសាងសង់មធ្យោបាយបញ្ជូនដែលត្រូវការនោះ ឱ្យទាន់ក្នុងរយៈពេលដែលគេត្រូវការមធ្យោបាយបញ្ជូននោះទេ ពេលនោះ សិទ្ធិសាងសង់និងដំណើរការមធ្យោបាយបញ្ជូននោះអាចនឹងផ្តល់ទៅឱ្យក្រុមហ៊ុនដែលមានសមត្ថភាព និងដែលអាចទទួលបានអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។

## គោលការណ៍ទី៥. ចំណុចដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវពិនិត្យមុនពេលសម្រេចចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស

មុនពេលសម្រេចផ្តល់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស សម្រាប់មធ្យោបាយបញ្ជូនណាមួយ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាថា មធ្យោបាយបញ្ជូនអគ្គិសនីនោះ ពិតជាមានផលប្រយោជន៍សាធារណៈ ពេលវេលាដាក់ឱ្យដំណើរការមធ្យោបាយបញ្ជូននោះ ពិតជាពេលវេលាដែលគេត្រូវការមធ្យោបាយបញ្ជូននោះ និងឥទ្ធិពលរបស់មធ្យោបាយបញ្ជូននោះលើការដំណើរការមធ្យោបាយបញ្ជូនដទៃទៀត ពិតជាល្អ ។ ចំពោះបញ្ហានេះ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវវាយតម្លៃដោយផ្អែកលើផែនការដែលបានចេញ ឬ បានយល់ព្រមដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រសិនបើ មធ្យោបាយបញ្ជូននោះមានកំណត់នៅក្នុងផែនការ ។ ដោយឡែក ប្រសិនបើមធ្យោបាយនោះពុំមានកំណត់នៅក្នុងផែនការនោះទេ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស បង្ហាញនូវភស្តុតាងនិងលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពនៃមធ្យោបាយបញ្ជូននោះ ទៅតាមការតម្រូវរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធ្វើការវាយតម្លៃអំពីអត្ថប្រយោជន៍នៃមធ្យោបាយបញ្ជូនអគ្គិសនីដែលស្នើសុំនោះ ។

## គោលការណ៍ទី៦. ការបើកចំហសម្រាប់ការប្រើប្រាស់មធ្យោបាយបញ្ជូនរបស់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ត្រូវបើកចំហដោយគ្មានការរើសអើងនូវការប្រើប្រាស់មធ្យោបាយបញ្ជូនរបស់ខ្លួនរហូតដល់កម្រិតព្រំដែនបច្ចេកទេសនៃមធ្យោបាយបញ្ជូននោះ ដូចដែលមាន

ចែងក្នុងបទប្បញ្ញត្តិ/កូដ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ ក្នុងករណី អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសបានចុះកិច្ចព្រមព្រៀងបញ្ជូនជាមួយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ផ្តល់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីប្រើអានុភាពទាំងមូលនៃមធ្យោបាយបញ្ជូនរបស់ខ្លួន ឬក៏កិច្ចព្រមព្រៀងបញ្ជូននោះហាមឃាត់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ក្នុងការអនុញ្ញាតឱ្យភាគីទីបីប្រើប្រាស់មធ្យោបាយបញ្ជូននោះ ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ត្រូវមានកាតព្វកិច្ចបើកចំហការប្រើប្រាស់មធ្យោបាយបញ្ជូនរបស់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនោះ ។

## គោលការណ៍ទី៧~ ផែនការពង្រីកការគ្រប់គ្រងរបស់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី

ក្នុងករណី ដែលអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីគ្រោងចុះកិច្ចព្រមព្រៀងបញ្ជូនជាមួយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ដើម្បីប្រើអានុភាពទាំងមូលនៃមធ្យោបាយបញ្ជូនរបស់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ពេលនោះ អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីត្រូវកំណត់នៅក្នុងកិច្ចព្រមព្រៀងនោះនូវជម្រើសសម្រាប់ខ្លួន ទិញយកមធ្យោបាយបញ្ជូននោះ នៅពេលអនាគត ។

## គោលការណ៍ទី៨~ ផែនការបង្កើនប្រសិទ្ធភាពក្នុងការដំណើរការមធ្យោបាយបញ្ជូន

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវតភ្ជាប់មធ្យោបាយបញ្ជូនរបស់អ្នកកាន់អាជ្ញាប័ណ្ណដទៃទៀតជាមួយមធ្យោបាយបញ្ជូនរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាបញ្ជូន ស្របតាមបទប្បញ្ញត្តិ/កូដ ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ ដើម្បីសម្រួលក្នុងការតភ្ជាប់នេះ អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវរក្សាទុកកន្លែងទំនេរនៅក្នុងបន្ទប់បញ្ជា និងនៅក្នុងទីលានតម្លើងឱ្យបានគ្រប់គ្រាន់ សម្រាប់តម្លើងឧបករណ៍និងបរិក្ខាផ្សេងៗ ដែលត្រូវពង្រីក និងតភ្ជាប់ជាមួយមធ្យោបាយបញ្ជូនអគ្គិសនី/មធ្យោបាយរងបញ្ជូនអគ្គិសនីដទៃទៀត នៅពេលអនាគត ។

## គោលការណ៍ទី៩~ លក្ខខណ្ឌសំខាន់ៗដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបញ្ចូលក្នុងខ្លឹមសារអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាថាខ្លឹមសារអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញឱ្យសេវាករអគ្គិសនី ត្រូវមានបញ្ចូលនូវលក្ខខណ្ឌសំខាន់ៗ ដូចខាងក្រោម :

១-អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ត្រូវគោរពតាមបទប្បញ្ញត្តិនិងកូដប្រព័ន្ធបណ្តាញ ដែលមានជាធរមាន ។

២-អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវដំណើរការមធ្យោបាយបញ្ជូនរបស់ខ្លួន ទៅតាមការណែនាំរបស់មជ្ឈមណ្ឌលបញ្ជា ។ កម្មវិធីនៃការផ្តាច់ចរន្តតាមផែនការ និងការផ្តាច់ចរន្តក្នុងគ្រាមានអាសន្ន សម្រាប់មធ្យោបាយបញ្ជូននេះ ត្រូវមានការយល់ព្រមពីមជ្ឈមណ្ឌលបញ្ជា ។

៣-នៅគ្រប់ពេល អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវផ្តល់នូវមធ្យោបាយគមនាគមន៍សមស្រប ដែលអាចធ្វើការជាមួយមធ្យោបាយគមនាគមន៍ដែលមាននៅក្នុងមជ្ឈមណ្ឌលបញ្ជា ដើម្បីធានាការទំនាក់ទំនងជាមួយមជ្ឈមណ្ឌលបញ្ជាភ្លាមៗ និងការផ្ទេរទិន្នន័យដំណើរការប្រព័ន្ធទៅឱ្យមជ្ឈមណ្ឌលបញ្ជា ។

៤-អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវតម្លើងនាឡិកាស្ទង់ និងបរិក្ខារួមផ្សំរបស់នាឡិកាស្ទង់សមស្រប សម្រាប់វាស់បរិមាណថាមពលដែលបានបញ្ជូនចូល និងបញ្ជូនចេញតាមមធ្យោបាយបញ្ជូនរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

# ជំពូក ៣

# គោលការណ៍សម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស សម្រាប់មធ្យោបាយរងបញ្ជូនអគ្គិសនី

## គោលការណ៍ទី១០. សិទ្ធិសាងសង់និងដំណើរការមធ្យោបាយរងបញ្ជូនអគ្គិសនីណាមួយ

មធ្យោបាយរងបញ្ជូនអគ្គិសនីមួយអាចត្រូវបានសាងសង់ និងដំណើរការដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ឬដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសឱ្យសេវាករអគ្គិសនីណាមួយ ដើម្បីធ្វើការសាងសង់និងដំណើរការមធ្យោបាយរងបញ្ជូនណាមួយ តែក្នុងគោលដៅផលប្រយោជន៍សាធារណៈពិតប្រាកដប៉ុណ្ណោះ ។

## គោលការណ៍ទី១១. ការបើកចំហសម្រាប់ការប្រើប្រាស់មធ្យោបាយបញ្ជូនរងរបស់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវបើកចំហដោយគ្មានការរើសអើងនូវការប្រើប្រាស់មធ្យោបាយរងបញ្ជូនអគ្គិសនីរបស់ខ្លួន រហូតដល់កម្រិតព្រំដែនបច្ចេកទេសនៃមធ្យោបាយរងបញ្ជូនអគ្គិសនីនោះ ដូចដែលមានចែងក្នុងបទប្បញ្ញត្តិ/កូដ ដែលកំណត់ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។ ក្នុងករណី

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសបានចុះកិច្ចព្រមព្រៀងបញ្ជូនជាមួយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ផ្តល់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីប្រើអានុភាពទាំងមូលនៃមធ្យោបាយរងបញ្ជូនអគ្គិសនីរបស់ខ្លួន ឬក៏កិច្ចព្រមព្រៀងបញ្ជូននោះហាមឃាត់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ក្នុងការអនុញ្ញាតឱ្យភាគីទីបីប្រើប្រាស់មធ្យោបាយរងបញ្ជូនអគ្គិសនីនោះ ពេលនោះ អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីត្រូវមានកាតព្វកិច្ចបើកចំហការប្រើប្រាស់មធ្យោបាយរងបញ្ជូនអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនោះ ។

## គោលការណ៍ទី១២៖ ផែនការបង្កើនប្រសិទ្ធភាពក្នុងការដំណើរការមធ្យោបាយរងបញ្ជូនអគ្គិសនី

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវតភ្ជាប់មធ្យោបាយរបស់អ្នកកាន់អាជ្ញាប័ណ្ណដទៃទៀត ជាមួយមធ្យោបាយរងបញ្ជូនអគ្គិសនីរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាបញ្ជូន ស្របតាមបទប្បញ្ញត្តិ/កូដ ដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

## គោលការណ៍ទី១៣៖ លក្ខខណ្ឌសំខាន់ៗដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវបញ្ចូលក្នុងខ្លឹមសារអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសសម្រាប់មធ្យោបាយរងបញ្ជូនអគ្គិសនី

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាថាខ្លឹមសារអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ដែលអាជ្ញាធរអគ្គិសនីបានចេញឱ្យសេវាករអគ្គិសនីសម្រាប់មធ្យោបាយរងបញ្ជូនអគ្គិសនី ត្រូវមានបញ្ចូលនូវល័ក្ខខ័ណ្ឌសំខាន់ៗ ដូចខាងក្រោម ៖

១-អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវគោរពតាមបទប្បញ្ញត្តិនិងកូដប្រព័ន្ធបណ្តាញនិងចែកចាយ ដែលមានជាធរមាន ។

២-អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវដំណើរការមធ្យោបាយរងរបស់ខ្លួន ទៅតាមការណែនាំរបស់មជ្ឈមណ្ឌលបញ្ជា នៅពេលមានការចេញគោលការណ៍ណែនាំពីមជ្ឈមណ្ឌលបញ្ជា ។ ក្នុងករណី មិនមានគោលការណ៍ណែនាំពីមជ្ឈមណ្ឌលបញ្ជាទេ អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តតាមបទពិសោធន៍ដែលប្រសើរបំផុតរបស់សហគ្រាស ។

៣-អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវតម្លើងនាឡិកាស្ទង់ និងបរិក្ខាររួមផ្សំរបស់នាឡិកាស្ទង់ឱ្យបានសមស្រប សម្រាប់វាស់បរិមាណថាមពលដែលបានបញ្ជូនចូល និងបានបញ្ជូនចេញតាមមធ្យោបាយរងបញ្ជូនអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

# ឯកសារពន្យល់សម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស

## ក. ប្រព័ន្ធបញ្ជូន និងបណ្តាញបញ្ជូន

ការផ្ទេរអគ្គិសនីជារូបភាពដុំក្នុងចម្ងាយវែង គឺត្រូវធ្វើឡើងតាមតង់ស្យុងខ្ពស់ ពីព្រោះវាមានលក្ខណៈសេដ្ឋកិច្ចជាង និងមានប្រសិទ្ធភាពជាង ។ ខ្សែបណ្តាញតង់ស្យុងខ្ពស់ដែលប្រើប្រាស់សម្រាប់ផ្ទេរអគ្គិសនីជារូបភាពដុំនេះ ហៅថា “ខ្សែបណ្តាញបញ្ជូន” ឬហៅថា “សៀគ្វីបញ្ជូន” ។ ជាធម្មតា ខ្សែបណ្តាញបញ្ជូនមួយភ្ជាប់រោងចក្រអគ្គិសនីឬអនុស្ថានីយមួយ ជាមួយនឹងរោងចក្រអគ្គិសនីឬអនុស្ថានីយផ្សេងទៀត ។ ត្រង់ស្វូរម៉ាទ័រដែលគេប្រើនៅរោងចក្រអគ្គិសនី គឺសម្រាប់តម្លើងតង់ស្យុងនៃអគ្គិសនីដែលផលិតពីតង់ស្យុងផលិត ទៅជាតង់ស្យុងបញ្ជូន ។ ត្រង់ស្វូរម៉ាទ័រដែលគេប្រើនៅអនុស្ថានីយ គឺសម្រាប់តម្លើងឬបញ្ចុះតង់ស្យុង ដើម្បីធ្វើការភ្ជាប់ចូលគ្នានូវខ្សែបណ្តាញបញ្ជូនដែលមានតង់ស្យុងខុសគ្នា ប្រព័ន្ធបញ្ជូនរង និង/ឬ ប្រព័ន្ធចែកចាយ ។ នៅក្នុងប្រព័ន្ធបញ្ជូន គឺមានខ្សែបណ្តាញបញ្ជូនច្រើនភ្ជាប់ចូលគ្នា និងអនុស្ថានីយមួយចំនួន ។ ភាគច្រើន ប្រព័ន្ធបញ្ជូនច្រើន តែប្រើខ្សែបណ្តាញអាកាសនិងចរន្តឆ្លាស់ ។ ប៉ុន្តែពេលខ្លះក៏មានប្រើចរន្តជាប់ ខ្សែកាបកប់ដី និងខ្សែកាបក្នុងទឹកដែរ ។

តង់ស្យុងនៃការបញ្ជូនត្រូវបានជ្រើសរើសទៅតាមបរិមាណនៃអគ្គិសនី និងចម្ងាយ ដែលត្រូវធ្វើការផ្ទេរ ។ បរិមាណអគ្គិសនីកាន់តែច្រើន និងចម្ងាយបញ្ជូនកាន់តែឆ្ងាយ គេត្រូវប្រើតង់ស្យុងកាន់តែខ្ពស់ ។ ជាធម្មតា ប្រព័ន្ធបញ្ជូនមួយប្រើប្រាស់តង់ស្យុងច្រើនលើសពីមួយ ។ តារាងទី ១ ខាងក្រោម ផ្តល់នូវកម្រិតតង់ស្យុងសំខាន់ៗដែលគេប្រើនៅក្នុងប្រព័ន្ធបញ្ជូនប្រទេសផ្សេងៗ ។

តារាងទី១ – តង់ស្យុងដែលគេប្រើប្រាស់ក្នុងការបញ្ជូន

| | **ប្រទេស** | **តង់ស្យុងបញ្ជូនសំខាន់ៗ** |
|---|---|---|
| 1 | ប្រទេសថៃ | 500 kV, 230 kV, 115 kV |
| 2 | ប្រទេសវៀតណាម | 500 kV, 220 kV, 110 kV |
| 3 | ប្រទេសឡាវ | 230 kV, 115 kV |
| 4 | ប្រទេសម៉ាឡេស៊ី | 500 kV, 275 kV, 132 kV |
| 5 | ប្រទេសមីយ៉ាន់ម៉ា | 230 kV, 132 kV, 66 kV |
| 6 | ប្រទេសចិន (ខេត្តយូណាន់) | 500 kV, 220 kV, 110 kV |
| 7 | ប្រទេសហ្វីលីពីន | 500 kV, 350 kV, 230 kV, 138 kV, 115 kV, 69 kV |
| 8 | ប្រទេសឥណ្ឌា | 400 kV, 220 kV, 132 kV |
| 9 | សហរដ្ឋអាមេរិក | 765 kV, 500 kV, 345 kV, 230 kV |
| 10 | ប្រទេសកម្ពុជា | 115 kV, 230 kV |

ប្រព័ន្ធបញ្ជូនភ្ជាប់រោងចក្រអគ្គិសនីទាំងអស់ជាមួយគ្នាទៅវិញទៅមក និងដឹកជញ្ជូនថាមពលអគ្គិសនីពីរោងចក្រអគ្គិសនីទាំងនោះ ទៅឱ្យប្រព័ន្ធចែកចាយ ។ ប្រព័ន្ធបញ្ជូនរង គឺជាផ្នែកមួយនៃប្រព័ន្ធបញ្ជូនដែលឋិតនៅចន្លោះប្រព័ន្ធបញ្ជូននិងប្រព័ន្ធចែកចាយ ។ ប្រព័ន្ធចែកចាយដឹកជញ្ជូនថាមពលអគ្គិសនីទៅឱ្យអតិថិជនលំនៅដ្ឋាន អតិថិជនពាណិជ្ជកម្ម និងអតិថិជនផ្សេងៗទៀត ។ អតិថិជនដែលទិញអគ្គិសនីតាមតង់ស្យុងខ្ពស់ ត្រូវភ្ជាប់ជាមួយប្រព័ន្ធបញ្ជូន ។ ប្រព័ន្ធបញ្ជូន ឬហៅម្យ៉ាងទៀតថា ប្រព័ន្ធអគ្គិសនីធំ គឺជាបណ្ដាញនៃរោងចក្រអគ្គិសនីសៀគ្វីបញ្ជូន និងអនុស្ថានីយ ។

## ខ. លំហូរនៃអគ្គិសនីនៅក្នុងប្រព័ន្ធបញ្ជូន

លំហូរនៃអគ្គិសនីពីរោងចក្រអគ្គិសនីមួយទៅអតិថិជនមួយ ធ្វើចលនាតាមរយៈខ្សែទាំងអស់ ដែលភ្ជាប់រោងចក្រអគ្គិសនីនិងអតិថិជននោះ មិនមែនធ្វើដំណើរតាមតែខ្សែណាដែលមានប្រវែងខ្លីជាងគេនោះទេ ។ គេពិបាកនឹងធ្វើការកំណត់ថា តើអគ្គិសនីធ្វើចលនាតាមផ្លូវដោយឡែកណាមួយ និងពិបាកនឹងត្រួតពិនិត្យលំហូររបស់វាឱ្យបានពិតប្រាកដណាស់ ។ ពុំមានវិស្វករបើកបិទណាមួយ អាចធ្វើការបើកឬបិទខ្សែដោយឡែកណាមួយ ដើម្បីបញ្ជាលំហូរអគ្គិសនី ឬកាត់ផ្ដាច់លំហូរអគ្គិសនីទាំងស្រុងលើខ្សែតាមរយៈការផ្ដាច់ប្រដាប់បើកបិទមួយបានឡើយ ។ លំហូរអគ្គិសនីពុំទទួលស្គាល់ផ្លូវលំហូរតាមកិច្ចសន្យា ឬម្ចាស់កម្មសិទ្ធិហេដ្ឋារចនាសម្ព័ន្ធឡើយ ។ លំហូរអគ្គិសនីនៅក្នុងប្រព័ន្ធបណ្ដាញមួយគោរពទៅតាមតែច្បាប់រូបវិទ្យាប៉ុណ្ណោះ ។

ចំពោះសៀគ្វីបញ្ជូនកំណត់មួយ ប៉ារ៉ាម៉ែត្រគន្លឹះចំនួន ៣ ជាអ្នកកំណត់លំហូរអគ្គិសនី : តង់ស្យុងនៃរបារខាងចុង, អាំប៉េដង់ (រ៉េស៊ីស្តង់សរុប) របស់ខ្សែ និងមុំនៃហ្វារវាងចុងដែលបញ្ជូននិងចុងដែលទទួល ។ អាំប៉េដង់នៃសៀគ្វីបញ្ជូនមួយអាស្រ័យនឹងប្រវែងខ្សែ និង លក្ខណៈលំអិតរបស់ខ្សែ ។ ផ្លូវដែលមានអាំប៉េដង់ទាប និងទាក់ទាញឱ្យមានលំហូរច្រើនជាងផ្លូវដែលមានអាំប៉េដង់ខ្ពស់ ។ នៅក្នុងសៀគ្វីបញ្ជូននៃបណ្ដាញណាមួយ អគ្គិសនីអាចធ្វើដំណើរតាមទិសដៅទាំងពីរ ។

រូបភាពទី១ – លំហូរនៅក្នុងប្រព័ន្ធអគ្គិសនី




ការផ្ទេរអគ្គិសនីពី A ទៅ B, A គឺជាអ្នកនាំចេញ ហើយ B គឺជាអ្នកនាំចូល ។

លំហូរអគ្គិសនីធ្វើដំណើរតាម ផ្លូវជាមូលដ្ឋានផង និង ផ្លូវស្របទិសដៅទាំងអស់ផង ។

នៅក្នុង ឧទាហរណ៍សាមញ្ញដែលបានបង្ហាញខាងលើ អគ្គិសនីដែលផ្គត់ពីរោងចក្រផលិតទៅឱ្យអតិថិជន អាចធ្វើដំណើរតាមខ្សែទាំងអស់ដែលភ្ជាប់គេទាំងពីរ ។ នៅពេលដែលអគ្គិសនីធ្វើដំណើរតាមផ្លូវដោយឡែកពីផ្លូវដែលបានកំណត់ គេហៅថា "លំហូរស្របទិសដៅ" ។ នៅពេលដែលការផ្ទេរអគ្គិសនីកើនឡើង លំហូរតាមផ្លូវជាមូលដ្ឋាន ក៏ដូចជាលំហូរតាមផ្លូវស្របទិសដៅកើនឡើងដូចគ្នា ។ ការរអាក់រអួលលើសៀគ្វីណាមួយ និងមានឥទ្ធិពលលើលំហូរនៃសៀគ្វីដ៏ទៃទៀតដែលនៅសល់ ។ ការប្រែប្រួលផលិតកម្ម ឬ ការប្រែប្រួលបន្ទុកនៅចំណុចណាមួយនៃប្រព័ន្ធបណ្តាញ និងធ្វើឱ្យមានការប្រែប្រួលនៃលំហូរអគ្គិសនីនៅក្នុងសៀគ្វីផ្សេងៗទៀត ។ ស្ថានភាពនេះអាចធ្វើឱ្យចរន្តអគ្គិសនីឡើងលើសកម្រិតដែលអនុញ្ញាតនៃសៀគ្វីណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់ស្ថិរភាពនៃប្រព័ន្ធ ។ ដូច្នេះ មុនពេលអនុញ្ញាតឱ្យបន្ថែមអានុភាពផលិតកម្មថ្មី ឬ បន្ទុកថ្មី ឬ សៀគ្វីបញ្ជូនថ្មីណាមួយ គឺទាមទារឱ្យមានការសិក្សាត្រឹមត្រូវពីប្រព័ន្ធទាំងមូល ។ ការសិក្សានោះត្រូវតែធ្វើឱ្យទាន់សម័យជានិច្ច ដើម្បីយល់ដឹងពីលទ្ធភាពនៃការលើសបន្ទុក តង់ស្យុងនៅតាមបណ្តាទីតាំងនានា និង ការបញ្ហាដំណើរការផ្សេងៗ ។ ដូច្នេះ ការសិក្សានិងការធ្វើផែនការទាមទារត្រូវធ្វើសម្រាប់ប្រព័ន្ធទាំងមូល ដោយស្ថាប័នមួយ ទោះបីជាផ្នែកនីមួយៗនៃប្រព័ន្ធ កាន់កាប់ដោយអ្នកធ្វើសេវាកម្មផ្សេងៗគ្នាក៏ដោយ ។

អគ្គិសនីធ្វើចលនាពីរោងចក្រផលិតទៅកាន់អតិថិជន តាមប្រព័ន្ធបញ្ជូននិងប្រព័ន្ធចែកចាយនៅក្នុងល្បឿនមួយជិតស្មើនឹងល្បឿននៃពន្លឺ ។ ដោយសារបច្ចុប្បន្ននេះ ពុំទាន់មានវិធីសាស្ត្រពិតប្រាកដណាមួយដើម្បីរក្សាទុកបរិមាណអគ្គិសនីក្នុងរូបភាពធំ ចំនួនសរុបនៃអគ្គិសនីដែលបានផលិតជាបន្តបន្ទាប់ ត្រូវតែស្មើនឹងបរិមាណដែលប្រើប្រាស់ជាបន្តបន្ទាប់ ។ ជារួម បរិមាណផលិតនៃរោងចក្រផលិតទាំងអស់ត្រូវតែស៊ីគ្នានឹងបរិមាណសរុបនៃបន្ទុកជាបន្តបន្ទាប់គ្នា និងការបាត់បង់នៅក្នុងប្រព័ន្ធ ។

ប្រព័ន្ធការពារ និងការក្រិតចំណុចដំណើរការនៃប្រព័ន្ធនេះ សម្រាប់ផ្នែកផ្សេងៗនៃប្រព័ន្ធបណ្តាញ ត្រូវការសម្របសម្រួលគ្នាឱ្យបានត្រឹមត្រូវ ដើម្បីឱ្យក្នុងករណីមានកំហូចកើតឡើងនៅផ្នែកណាមួយ ប្រព័ន្ធការពារត្រូវតែអាចកាត់ផ្តាច់ផ្នែកដែលមានកំហូចនោះ ចេញពីបណ្តាញឱ្យបានឆាប់ ។ ជាទូទៅ គណៈកម្មការបច្ចេកទេសដែលមានសមាជិកមកពីអ្នកកាន់អាជ្ញាប័ណ្ណផ្សេងៗ ដែលជាអ្នកដំណើរការលើមធ្យោបាយផលិតកម្ម និងបញ្ជូននោះ ត្រូវទទួលបន្ទុកក្នុងការសម្រេចចិត្តទាក់ទងនឹងប្រព័ន្ធការពារ ។

## គ. មជ្ឈមណ្ឌលបញ្ជា

ដើម្បីឱ្យប្រព័ន្ធបណ្តាញបញ្ជូនដំណើរការដោយប្រក្រតីគឺទាមទារការសម្របសម្រួលដោយផ្ទាល់ និងការតាមដានត្រួតពិនិត្យមើលប្រព័ន្ធបណ្តាញ ។ ការងារនេះត្រូវអនុវត្តដោយមជ្ឈមណ្ឌលបញ្ជា ។ មជ្ឈមណ្ឌលបញ្ជាមួយធ្វើការចាត់ចែងសម្របសម្រួលដំណើរការនៃធាតុទាំងឡាយរបស់ប្រព័ន្ធ និងទទួលខុសត្រូវដំណើរការប្រព័ន្ធអគ្គិសនីដែលឋិតនៅក្នុងរង្វង់តំបន់ភូមិសាស្ត្រមួយហៅថាតំបន់បញ្ជា ដោយមិនគិតថា ហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម និង/ឬ បណ្តាញបញ្ជូននៅក្នុងតំបន់នោះជារបស់អ្នកណាឡើយ ។ ប្រព័ន្ធអគ្គិសនី ដែលមានទំហំធំច្រើនមានមជ្ឈមណ្ឌលបញ្ជាច្រើនលើសពីមួយ ។ ប្រព័ន្ធមួយដែលដំណើរការដោយមជ្ឈមណ្ឌលបញ្ជាមួយ

ធ្វើការភ្ជាប់ជាមួយប្រព័ន្ធដទៃទៀតដែលដំណើរការដោយមជ្ឈមណ្ឌលបញ្ជាផ្សេងទៀត ដោយខ្សែបណ្តាញបញ្ជូនតភ្ជាប់មួយចំនួន ។

នៅប្រទេសថៃ EGAT មានមជ្ឈមណ្ឌលបញ្ជាចំនួនប្រាំមួយ ។ មជ្ឈមណ្ឌលបញ្ជាកណ្តាល ដែលមានទីតាំងឋិតនៅទីស្នាក់ការកណ្តាលរបស់ EGAT នៅខេត្ត Non - thaburi ទទួលខុសត្រូវបញ្ជាទាំងប្រព័ន្ធបញ្ជូនដែលមានតង់ស្យុង ២៣០ គីឡូវ៉ុល និងខ្ពស់ជាង នៅទូទាំងប្រទេសថៃ ទាំងខ្សែបណ្តាញបញ្ជូនដែលតភ្ជាប់ប្រព័ន្ធ EGAT ជាមួយប្រព័ន្ធអគ្គិសនីឡាវ និងប្រព័ន្ធអគ្គិសនីម៉ាឡេស៊ី និងទាំងរោងចក្រអគ្គិសនីដែលមានអនុភាព ១០០ មេហ្គាវ៉ាត់ ឬខ្ពស់ជាង ។ មជ្ឈមណ្ឌលបញ្ជាតាមតំបន់ចំនួន ៥ ទៀត ដូចអធិប្បាយខាងក្រោម ទទួលខុសត្រូវបញ្ជាប្រព័ន្ធបញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ុល និងទាបជាង និងបញ្ជារោងចក្រអគ្គិសនីដែលមានអនុភាពទាបជាង ១០០ មេហ្គាវ៉ាត់ ដែលឋិតនៅក្នុងតំបន់របស់ខ្លួន ។

១-មជ្ឈមណ្ឌលបញ្ជារដ្ឋធានី ដែលមានទីតាំងឋិតនៅក្នុងទីស្នាក់ការកណ្តាល EGAT នៅខេត្ត Nonthaburi ទទួលខុសត្រូវលើតំបន់បាងកក និងខេត្តដែលនៅជុំវិញ សរុបចំនួន ៤ ខេត្ត ។

២-មជ្ឈមណ្ឌលបញ្ជាតំបន់វាលរាបកណ្តាល ដែលមានទីតាំងឋិតនៅក្នុងទីស្នាក់ការកណ្តាល EGAT នៅខេត្ត Nonthaburi ទទួលខុសត្រូវលើតំបន់ដែលមាន ខេត្តចំនួន ២៣ ក្នុងតំបន់វាលរាប លើកលែងតែបាងកកនិងខេត្តជាប់ក្រុងបាងកក ។

៣-មជ្ឈមណ្ឌលបញ្ជាសំរាប់ភូមិភាគឥសាន្ត ដែលមានទីតាំងឋិតនៅក្នុងអនុស្ថានីយតង់ស្យុងខ្ពស់ Khon Kaen 1 នៅស្រុក Mueang ខេត្ត Khon Kaen ទទួលខុសត្រូវលើតំបន់ដែលមានខេត្តចំនួន ១៩ ក្នុងតំបន់ភូមិភាគឦសាន ។

៤-មជ្ឈមណ្ឌលបញ្ជាសំរាប់ភូមិភាគខាងត្បូង ដែលមានទីតាំងឋិតនៅអនុស្ថានីយតង់ស្យុងខ្ពស់ Lamphura នៅស្រុក Huai Yot ខេត្ត Trang ទទួលខុសត្រូវលើតំបន់ដែលមានខេត្តចំនួន ១៦ ក្នុងតំបន់ភូមិភាគខាងត្បូង ។

៥-មជ្ឈមណ្ឌលបញ្ជាសំរាប់ភូមិភាគជើង ដែលមានទីតាំងឋិតនៅអនុស្ថានីយតង់ស្យុងខ្ពស់ Phitsa-nulok នៅស្រុក Mueang ខេត្ត Phitsanulok ទទួលខុសត្រូវលើតំបន់ដែលមានខេត្តចំនួន ១៤ ក្នុងតំបន់ភូមិភាគខាងជើង ។

ប្រទេសវៀតណាមមានមជ្ឈមណ្ឌលបញ្ជាជាតិមួយ ដែលមានទីតាំងឋិតនៅក្នុងទីក្រុងហាណូយ ដែលបញ្ជាប្រព័ន្ធអគ្គិសនីរបស់វៀតណាមទាំងមូល ដោយបញ្ជាផ្ទាល់លើខ្សែបណ្តាញបញ្ជូន ៥០០ គីឡូវ៉ុល និងរោងចក្រអគ្គិសនីធំៗ និងបញ្ជាដោយប្រយោល លើខ្សែបណ្តាញបញ្ជូន ២២០ គីឡូវ៉ុល តាមរយៈមជ្ឈមណ្ឌលបញ្ជាតំបន់ (តំបន់ខាងជើង, តំបន់កណ្តាល និងតំបន់ខាងត្បូង) ។

នៅក្នុងសហគ្រាសដែលរួមបញ្ចូលសេវាកម្មទាំងអស់ មជ្ឈមណ្ឌលបញ្ជាគឺជារបស់សហគ្រាស ។ ក្នុងប្រទេសជាច្រើន ដែលការងារបញ្ជូនអគ្គិសនីត្រូវបានបំបែកពីការងារដទៃទៀត ក្រុមហ៊ុនបញ្ជូនអគ្គិសនីដែលគ្រប់គ្រងដោយរដ្ឋ គឺជាម្ចាស់និងជាអ្នកដំណើរការមជ្ឈមណ្ឌលបញ្ជា ។ ឧទាហរណ៍ដូចជា ប្រទេសអង់គ្លេស និងឥណ្ឌា ។ នៅក្នុងប្រទេសទាំង២នេះ ក្រុមហ៊ុនបញ្ជូនអគ្គិសនីដែលដំណើរការមជ្ឈមណ្ឌលបញ្ជា មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាម្ចាស់កម្មសិទ្ធរោងចក្រអគ្គិសនី ឬធ្វើពាណិជ្ជកម្មអគ្គិសនីឡើយ ។ ការធ្វើដូច្នេះ គឺដើម្បីចៀសវាងការប្រទាំងប្រទើសនឹងផលប្រយោជន៍ និងដើម្បីបង្កើតនូវការធានាទុកចិត្តមួយ ក្នុងការដំណើរការមជ្ឈមណ្ឌលបញ្ជា ។ នៅប្រទេសផ្សេងៗទៀត ដូចជាសហរដ្ឋអាមេរិក មជ្ឈមណ្ឌលបញ្ជាច្រើនដំណើរការដោយអ្នកដំណើរការឯករាជ ដែលគេហៅថា Independent System Operators (ISO) ។

ភារកិច្ចដែលមជ្ឈមណ្ឌលបញ្ជាត្រូវធ្វើជាទូទៅ មានដូចខាងក្រោម :

១– ត្រួតពិនិត្យមើលនិងបញ្ជាដំណើរការប្រព័ន្ធអគ្គិសនី ដើម្បីធានាឱ្យការផ្គត់ផ្គង់អគ្គិសនី មានចិរភាព និងគ្រប់គ្រាន់ ប្រកបដោយកម្រិតគុណភាពមួយគ្រប់គ្រាន់ អាចទទួលយកបាន

២–ធ្វើការដោះដូរថាមពលអគ្គិសនីជាមួយប្រព័ន្ធប្រទេសជិតខាង

៣–ដាក់កម្មវិធីឱ្យធ្វើការជួសជុលថែទាំរោងចក្រអគ្គិសនីនិងខ្សែបណ្តាញបញ្ជូនដែលមានតង់ស្យុងខ្ពស់

៤–រៀបចំកម្មវិធីដំណើរការប្រព័ន្ធអគ្គិសនី ប្រចាំថ្ងៃ ប្រចាំអាទិត្យ ប្រចាំខែ

៥–កត់ត្រានិងថែរក្សាទិន្នន័យ

ដើម្បីធ្វើការត្រួតពិនិត្យមើលប្រព័ន្ធអគ្គិសនីជាប់ជាប្រចាំ មជ្ឈមណ្ឌលបញ្ជាត្រូវទទួលប្រព័ន្ធទិន្នន័យពីរោងចក្រអគ្គិសនី និងពីអនុស្ថានីយនានា ។ តាមរយៈប្រព័ន្ធទំនាក់ទំនងដ៏ត្រឹមត្រូវ (ដែលមានប្រដាប់វាស់ស្ទង់ និងប្រដាប់កត់ត្រានិងបញ្ជូនទិន្នន័យពីចម្ងាយ) មជ្ឈមណ្ឌលបញ្ជាអាចទទួលព័ត៌មានជាប្រចាំអំពីអនុភាពបញ្ចេញពីរោងចក្រអគ្គិសនី លំហូរនៃចរន្តអគ្គិសនីនៅក្នុងខ្សែបណ្តាញបញ្ជូន ការតភ្ជាប់ជាមួយប្រព័ន្ធប្រទេសជិតខាង និងល័ក្ខខ័ណ្ឌនៃប្រព័ន្ធ ។ មជ្ឈមណ្ឌលបញ្ជាប្រើប្រាស់ព័ត៌មានទាំងនេះ សម្រាប់ធានាស្ថិរភាពរបស់ប្រព័ន្ធ ដោយតាមដានលក្ខណៈវិនិច្ឆ័យនៃស្ថិរភាព និងរក្សាតុល្យភាពនៃកម្មវិធីដោះដូរទៅវិញទៅមកជាមួយមជ្ឈមណ្ឌលបញ្ជាដទៃទៀត ។

ជាមួយនឹងបច្ចេកវិជ្ជាទំនើប មជ្ឈមណ្ឌលបញ្ជាបច្ចុប្បន្ននេះ អាចទទួលទិន្នន័យនៃប្រព័ន្ធអគ្គិសនីតាមរយៈគមនាគមន៍ជាមួយឧបករណ៍ដែលមានខ្សែទំនាក់ទំនង ឬអាចបញ្ចូលកម្មវិធីបញ្ជាបានតម្លើងនៅនឹងទីកន្លែងចង់ដឹងទិន្នន័យ ។ ដើម្បីគោលបំណងនេះ គេប្រើឧបករណ៍បញ្ជូនទិន្នន័យពីចម្ងាយហៅថា **Remote Terminal Units (RTUs)** ឬ **Intelligent Electronic Devices (IEDs)** តម្លើងនៅនឹងទីកន្លែង ។ ព័ត៌មាននេះ

ត្រូវបានបញ្ជូនទៅឱ្យមជ្ឈមណ្ឌលបញ្ជាតាមរយៈប្រព័ន្ធ **Supervisory Control and Data Acquisition (SCADA)** ។

គោលបំណងសំខាន់នៃការបញ្ជាប្រព័ន្ធអគ្គិសនីគឺ :

១-ផ្គត់ផ្គង់ថាមពលអគ្គិសនីឱ្យមានចីរភាពដល់អ្នកប្រើប្រាស់

២-រក្សាកម្រិតគុណភាពនៃការផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់គ្រាន់ (គិតទាំង ហ្វ្រេកង់ និង តង់ស្យុង)

៣-ធានាដំណើរការនៃប្រព័ន្ធអគ្គិសនី

៤-ដំណើរការប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ចនៃប្រព័ន្ធអគ្គិសនី ។

ដើម្បីឱ្យប្រព័ន្ធអគ្គិសនីធំមួយអាចដំណើរការប្រកបដោយស្ថិរភាព ប្រព័ន្ធនេះត្រូវរៀបចំ និងចាត់ចែងដំណើរការ ទៅតាមគោលការណ៍ដូចខាងក្រោម :

- បរិមាណផលិតសរុបនៅខណៈណាមួយត្រូវតែស្មើនឹងបរិមាណដែលប្រើប្រាស់សរុបបូកនឹងបរិមាណដែលបាត់បង់គិតទាំងបរិមាណបាត់បង់លើប្រព័ន្ធបញ្ជូន និងទាំងបរិមាណបាត់បង់លើប្រព័ន្ធចែកចាយ នៅខណៈនោះ
- លំហូរនៃចរន្តអគ្គិសនីតាមប្រព័ន្ធបញ្ជូនត្រូវតែអនុលោមទៅច្បាប់រូបវិទ្យា និងមិនអាចហូរតាមខ្សែពិសេសណាមួយឡើយ
- ប្រព័ន្ធនេះត្រូវតែរៀបចំយ៉ាងណាឱ្យមានអនុភាពបំរុងសម្រាប់ផលិតកម្ម និងអនុភាពបំរុងសម្រាប់ការបញ្ជូន ដើម្បីកុំឱ្យមានការផ្តាច់សេវា នៅពេលមានលំអៀងកើតឡើង ។

## ឃ-ប្រព័ន្ធបញ្ជូនរង និងលំហូរនៃអគ្គិសនីនៅក្នុងប្រព័ន្ធបញ្ជូនរង

ប្រព័ន្ធបញ្ជូនរង គឺជាប្រព័ន្ធមួយដែលភ្ជាប់ប្រព័ន្ធបញ្ជូនជាមួយប្រព័ន្ធចែកចាយ ដើម្បីធ្វើការផ្គត់ផ្គង់អគ្គិសនីឱ្យទៅដល់អ្នកប្រើប្រាស់ ។ តង់ស្យុងនៃប្រព័ន្ធបញ្ជូនរងជាធម្មតាទាបជាងតង់ស្យុងនៃប្រព័ន្ធបញ្ជូន ។ តង់ស្យុងនៃប្រព័ន្ធបញ្ជូនរងដែលគេប្រើប្រាស់នៅក្នុងប្រទេសផ្សេងៗ មាន 66 kV, 33 kV, 22 kV, 11 kV ។ល។ ជាទូទៅ ប្រព័ន្ធបញ្ជូនរងច្រើនតែមានផ្លូវលំហូរអគ្គិសនីតែមួយ ហើយតិចណាស់ដែលមានផ្លូវស្របទិសដៅ ។ បរិមាណនៃលំហូរអគ្គិសនី និងទំហំនៃតំបន់ដែលផ្គត់ផ្គង់ដោយប្រព័ន្ធបញ្ជូនរង តូចជាងធៀបទៅនឹងប្រព័ន្ធបញ្ជូន ។ ដោយសារមូលហេតុនេះហើយ លំអៀងលើប្រព័ន្ធបញ្ជូនរង មិនសូវជាមានឥទ្ធិពលលើដំណើរការនៃផ្នែកផ្សេងៗទៀតរបស់ប្រព័ន្ធឡើយ ។ នៅក្នុងប្រទេសភាគច្រើន ប្រព័ន្ធបញ្ជូនរងមួយច្រើនផ្គត់ផ្គង់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយមួយ ។ ការធ្វើផែនការ និងដំណើរការប្រព័ន្ធបញ្ជូនរង មិនទាមទារត្រូវធ្វើការសម្របសម្រួលធំដុំ ដូចជាក្នុងករណីខ្សែបណ្តាញបញ្ជូនឡើយ ។

## ង-ប្រព័ន្ធបណ្តាញបញ្ជូនរបស់ព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៦)

ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន គឺជាប្រព័ន្ធបែកខ្ញែកគ្នា និងជាប្រព័ន្ធទោល

លើកលែងតែប្រព័ន្ធរាជធានីភ្នំពេញ ។ មានតែប្រព័ន្ធរាជធានីភ្នំពេញប៉ុណ្ណោះ ដែលមានខ្សែបណ្តាញតង់ស្យុងខ្ពស់ (១១៥គីឡូវ៉ុល) ។ ប្រព័ន្ធបណ្តាញបញ្ជូនរាជធានីភ្នំពេញមានខ្សែបណ្តាញ ១១៥ គីឡូវ៉ុលជុំវិញភ្នំពេញ និងខ្សែបណ្តាញ ១១៥ គីឡូវ៉ុល ភ្ជាប់ស្ថានីយវារីអគ្គិសនីគីរីរម្យមកភ្នំពេញ ។ ប្រព័ន្ធនេះតភ្ជាប់អនុស្ថានីយ ៣ នៅភ្នំពេញ រោងចក្រអគ្គិសនីរបស់អគ្គិសនីកម្ពុជា រោងចក្រអគ្គិសនីរបស់ផលិតករអគ្គិសនីឯករាជ និងអនុស្ថានីយនៅខេត្តកំពង់ស្ពឺ ។ ប្រព័ន្ធនេះបញ្ជាដោយស្ថានីយបញ្ជាមួយនៅភ្នំពេញ ។ ខ្សែបណ្តាញបញ្ជូន និងស្ថានីយបញ្ជា គឺជារបស់អគ្គិសនីកម្ពុជា ។ អគ្គិសនីកម្ពុជា គឺជាអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីដែលទទួលនូវសិទ្ធិគ្រប់គ្រងបណ្តាញបញ្ជូនទូទាំងព្រះរាជាណាចក្រកម្ពុជា ។

កម្ពុជាមានផែនការដ៏មុតមាំដើម្បីអភិវឌ្ឍប្រព័ន្ធបណ្តាញតង់ស្យុងខ្ពស់ នៅក្នុងព្រះរាជាណាចក្រម្ពុជា ដើម្បីភ្ជាប់ទីក្រុងនិងតំបន់ទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងផ្គត់ផ្គង់អគ្គិសនីតាមរយៈខ្សែបណ្តាញដល់ប្រជាជនរបស់ខ្លួន ។ តាមការខិតខំបច្ចុប្បន្ន គម្រោងដែលឋិតនៅក្នុងផែនការសាងសង់ មានដូចខាងក្រោម :

១-ខ្សែបណ្តាញ ២៣០ គីឡូវ៉ុល ភ្ជាប់ពីភ្នំពេញទៅប្រទេសវៀតណាម ដោយមានអនុស្ថានីយនៅតាកែវ និងនៅភ្នំពេញ

២-ខ្សែបណ្តាញ ២៣០ គីឡូវ៉ុល ពីតាកែវទៅកំពត ដោយមានអនុស្ថានីយនៅកំពត

៣-ខ្សែបណ្តាញ ១១៥ គីឡូវ៉ុល ពីប្រទេសថៃ មកសៀមរាប និងបាត់ដំបង ដែលមានអនុស្ថានីយនៅបន្ទាយមានជ័យ សៀមរាប និងបាត់ដំបង

៤-ខ្សែបណ្តាញ ២៣០ គីឡូវ៉ុល ពីកំពតទៅក្រុងព្រះសីហនុ ដោយមានអនុស្ថានីយនៅវាលរេញ និងក្រុងព្រះសីហនុ ។

ហេដ្ឋារចនាសម្ព័ន្ធនៅចំណុចទី១, ទី២ និងទី៤ ដែលជាកម្មសិទ្ធិរបស់អគ្គិសនីកម្ពុជា រួមជាមួយនឹងប្រព័ន្ធបណ្តាញបញ្ជូនដែលមានស្រាប់នៅភ្នំពេញ នឹងបង្កើតទៅជាប្រព័ន្ធបញ្ជូនភាគខាងត្បូង ឬហៅថាប្រព័ន្ធបញ្ជូនភ្នំពេញ ហើយនឹងត្រូវត្រួតពិនិត្យបញ្ជាដោយមជ្ឈមណ្ឌលបញ្ជានៅភ្នំពេញ ។ ហេដ្ឋារចនាសម្ព័ន្ធនៅចំណុច ៣ គឺជាកម្មសិទ្ធិរបស់អ្នកវិនិយោគឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយអគ្គិសនីកម្ពុជា និងដែលបង្កើតជាប្រព័ន្ធបណ្តាញបញ្ជូនភាគខាងលិច ហើយនឹងត្រូវត្រួតពិនិត្យបញ្ជាដោយមជ្ឈមណ្ឌលបញ្ជាមួយឋិតនៅតំបន់នោះដែលគ្រប់គ្រងដោយអគ្គិសនីកម្ពុជា ។

## ច-ការអភិវឌ្ឍន៍ប្រព័ន្ធបណ្តាញបញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា

ប្រព័ន្ធបណ្តាញបញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា កំពុងតែមានការវិវត្តន៍យ៉ាងលឿន ។ ដើម្បីអនុវត្តផែនការរបស់រាជរដ្ឋាភិបាល ក្នុងការផ្គត់ផ្គង់អគ្គិសនីដោយបណ្តាញឱ្យបានកាន់តែច្រើនតំបន់ គេត្រូវធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូននិងអនុស្ថានីយកាន់តែច្រើន ។ ការតភ្ជាប់គ្នានៃប្រព័ន្ធបញ្ជូនរបស់បណ្តាប្រទេស

ក្នុងមហាអនុតំបន់ទន្លេមេគង្គ ក៏កំពុងត្រូវគេពិចារណាផងដែរ ។ ខ្សែបណ្តាញបញ្ជូន និងអនុស្ថានីយថ្មីៗ អាចត្រូវសាងសង់ដោយអ្នកសាងសង់ ដូចខាងក្រោម ៖

១-ដោយអគ្គិសនីកម្ពុជា អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសំរាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ៖ អគ្គិសនីកម្ពុជាពុំមានថវិកាគ្រប់គ្រាន់សម្រាប់វិនិយោគខ្សែបណ្តាញបញ្ជូនថ្មីៗដោយខ្លួនឯងឡើយ ជាធម្មតាគឺពឹងផ្អែកលើហិរញ្ញប្បទានពីខាងក្រៅ ។ ដូច្នេះ អគ្គិសនីកម្ពុជាអាចមានលទ្ធភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធណាដែលគេអាចស្នើសុំហិរញ្ញប្បទានពីខាងក្រៅប៉ុណ្ណោះ ។

២-ដោយអ្នកវិនិយោគរោងចក្រអគ្គិសនីធំថ្មីណាមួយ ៖ ខ្សែបណ្តាញបញ្ជូនដែលភ្ជាប់រោងចក្រអគ្គិសនីនោះជាមួយប្រព័ន្ធបណ្តាញ ។ ដើម្បីធ្វើការបញ្ជូនអគ្គិសនីដែលបានផលិតពីរោងចក្ររបស់គេនេះទៅប្រព័ន្ធបណ្តាញ អ្នកវិនិយោគរោងចក្រអគ្គិសនីត្រូវធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូននេះ នៅក្នុងក្របខ័ណ្ឌនៃគម្រោងរោងចក្ររបស់គេ ។

៣-ដោយម្ចាស់រោងចក្រឧស្សាហកម្មធំណាមួយ ៖ រោងចក្រឧស្សាហកម្មឬអ្នកប្រើប្រាស់ធំ ដែលត្រូវការបរិមាណអគ្គិសនីចំនួនច្រើន អាចធ្វើការសាងសង់ខ្សែភ្ជាប់ផ្ទាល់ពីប្រព័ន្ធបញ្ជូនមកបន្ទុករបស់ខ្លួន ដើម្បីទទួលការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញបញ្ជូន ។

៤-ដោយអ្នកធ្វើសេវាកម្មបញ្ជូនអគ្គិសនី ៖ សហគ្រិនមួយអាចធ្វើការសាងសង់ខ្សែបណ្តាញមួយ ដើម្បីផ្តល់សេវាបញ្ជូនឱ្យអ្នកកាន់អាជ្ញាប័ណ្ណ/អ្នកប្រើប្រាស់ដោយឡែកណាមួយ ឬឱ្យអ្នកកាន់អាជ្ញាប័ណ្ណ/អ្នកប្រើប្រាស់មួយចំនួន ។

៥-ដោយអ្នកធ្វើសេវាកម្មបញ្ជូនសម្រាប់ច្រើនប្រទេស ៖ ខ្សែបណ្តាញបញ្ជូនដែលពង្រីកចេញផុតពីព្រំដែនប្រទេសកម្ពុជា អាចត្រូវសាងសង់ (i) ដើម្បីនាំចូលអគ្គិសនីពីប្រទេសជិតខាង, (ii) ដើម្បីនាំអគ្គិសនីចេញពីប្រទេសកម្ពុជា, (iii) ដើម្បីភ្ជាប់ប្រព័ន្ធរបស់ប្រទេសកម្ពុជាជាមួយប្រព័ន្ធនៃប្រទេសផ្សេងទៀត និង (iv) ដើម្បីតភ្ជាប់ប្រព័ន្ធរបស់បណ្តាប្រទេសដទៃទៀត ដែលគ្មានការតភ្ជាប់ជាមួយប្រព័ន្ធរបស់ប្រទេសកម្ពុជា ។

## ឆ-ការអភិវឌ្ឍន៍ប្រព័ន្ធបណ្តាញបញ្ជូនរង នៅក្នុងព្រះរាជាណាចក្រកម្ពុជា

ដើម្បីធ្វើយ៉ាងណាឱ្យការផ្គត់ផ្គង់ពីប្រព័ន្ធបណ្តាញបញ្ជូនអាចទៅដល់អ្នកប្រើប្រាស់ គេត្រូវការខ្សែបណ្តាញតង់ស្យុងមធ្យម ដើម្បីនាំអគ្គិសនីពីអនុស្ថានីយទៅឱ្យប្រព័ន្ធចែកចាយ ។ នៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រព័ន្ធចែកចាយបច្ចុប្បន្ននេះគឺជាប្រព័ន្ធទោលដែលធ្វើការចែកចាយអគ្គិសនីតាមភូមិឬទីប្រជុំជននីមួយៗ ហើយជារបស់អ្នកធ្វើសេវាកម្មខុសៗគ្នា ។ ស្ថានភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជានេះគឺខុសពីប្រទេសផ្សេងៗដទៃទៀត ដែលមានអ្នកធ្វើសេវាកម្មតែមួយផ្តល់សេវាកម្មចែកចាយលើតំបន់ធំមួយដែលមានភូមិឬទីប្រជុំជនច្រើន ។ ក្នុងព្រះរាជាណាចក្រកម្ពុជា ម្ចាស់ប្រព័ន្ធបណ្តាញបញ្ជូនរង និងម្ចាស់ប្រព័ន្ធចែកចាយ អាចជាអ្នក

ទីទៃពីគ្នា ។ ខ្សែបណ្តាញបញ្ជូនរងមួយអាចផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយច្រើនលើសពីមួយ ។ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាថា មិនមានការរើសអើងឬដាក់ចំណាត់ការខុសគ្នា ចំពោះការដំណើរការប្រព័ន្ធបណ្តាញបញ្ជូនរងផ្សេងគ្នាឡើយ ។ ដោយសារមូលហេតុនេះហើយ ទើបមានការចាំបាច់ត្រូវគ្រប់គ្រងប្រព័ន្ធបណ្តាញបញ្ជូនរង តាមផ្លូវមួយផ្សេង គឺគ្រប់គ្រងវាដូចជាខ្សែបណ្តាញបញ្ជូន ប៉ុន្តែមិនយកចិត្តទុកដាក់ខ្លាំងលើ ការធ្វើផែនការនិងដំណើរការទេ ។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រព័ន្ធបណ្តាញបញ្ជូនរងអាចសាងសង់ដោយអ្នកសាងសង់ ដូចខាងក្រោម :

១-ខ្សែបណ្តាញតង់ស្យុងមធ្យមអាចសាងសង់ដោយអគ្គិសនីកម្ពុជា ។ ក្នុងស្ថានភាពបច្ចុប្បន្ន ខ្សែបណ្តាញតង់ស្យុងមធ្យមភាគច្រើនគឺជារបស់អគ្គិសនីកម្ពុជា ។ រាជរដ្ឋាភិបាលក៏មានផែនការតម្រូវឱ្យអគ្គិសនីកម្ពុជាវិនិយោគសាងសង់ខ្សែបណ្តាញតង់ស្យុងមធ្យម ដើម្បីធ្វើការបញ្ជូនអគ្គិសនីពីអនុស្ថានីយទៅឱ្យប្រព័ន្ធចែកចាយនៅតាមភូមិ ឬតាមទីប្រជុំជនដែរ ។ អគ្គិសនីកម្ពុជាអាចស្នើសុំហិរញ្ញប្បទានពីខាងក្រៅសម្រាប់ការសាងសង់នេះ ដោយបញ្ចូលការសាងសង់នេះទៅក្នុងគម្រោងពង្រីកខ្សែបណ្តាញបញ្ជូន ឬក៏ដាក់ដោយឡែក ឬក៏វិនិយោគសាងសង់ខ្សែបណ្តាញនេះ ដោយទុនខ្លួនឯងផ្ទាល់ ។

២-អ្នកវិនិយោគសាងសង់រោងចក្រអគ្គិសនីមួយក៏អាចសាងសង់ខ្សែបណ្តាញតង់ស្យុងមធ្យម ដើម្បីបញ្ជូនអគ្គិសនីដែលបានផលិតទៅឱ្យប្រព័ន្ធបណ្តាញបញ្ជូនតាមតង់ស្យុងមធ្យម ឬ លក់អគ្គិសនីទៅឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ដែលនៅតាមភូមិ ឬតាមទីប្រជុំជននានាបានដែរ ។

៣-អ្នកប្រើប្រាស់ធុនធំមួយក៏អាចធ្វើការសាងសង់ខ្សែបណ្តាញតង់ស្យុងមធ្យម ដើម្បីទទួលការផ្គត់ផ្គង់អគ្គិសនីពីអនុស្ថានីយតាមតង់ស្យុងមធ្យមបានដែរ ។ នៅក្នុងករណីដ៏កម្រខ្លះ ខ្សែបណ្តាញខាងលើនេះក៏អាចត្រូវបានប្រើប្រាស់ ដើម្បីផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនៃភូមិណាមួយ ឬអ្នកប្រើប្រាស់ផ្សេងទៀតបិតនៅតាមគន្លងខ្សែ ដោយយកថ្លៃឈ្នួលខ្សែ ឬក៏ដោយការលក់អគ្គិសនីឱ្យ ។

៤-អ្នកកាន់អាជ្ញាប័ណ្ណចែកចាយមួយក៏អាចសាងសង់ខ្សែបណ្តាញតង់ស្យុងមធ្យម ដើម្បីទទួលការផ្គត់ផ្គង់អគ្គិសនីពីអនុស្ថានីយ ឬពីរោងចក្រអគ្គិសនីដែរ ។ អ្នកកាន់អាជ្ញាប័ណ្ណចែកចាយអាចប្រើប្រាស់ខ្សែបណ្តាញតង់ស្យុងមធ្យមនេះ ដើម្បីផ្គត់ផ្គង់អគ្គិសនីឱ្យទៅអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀត ដោយយកថ្លៃឈ្នួលខ្សែ ឬក៏លក់អគ្គិសនីឱ្យ ។

៥-អ្នកធ្វើសេវាកម្មឯករាជមួយក៏អាចសាងសង់ខ្សែបណ្តាញតង់ស្យុងមធ្យម ដើម្បីផ្គត់ផ្គង់ទៅអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ដោយយកថ្លៃឈ្នួលខ្សែ ឬក៏លក់អគ្គិសនីឱ្យ ។

## ៥-ការអភិវឌ្ឍន៍មជ្ឈមណ្ឌលបញ្ជានៅក្នុងព្រះរាជាណាចក្រកម្ពុជា

អគ្គិសនីកម្ពុជាមានមជ្ឈមណ្ឌលបញ្ជាមួយនៅរាជធានីភ្នំពេញ សម្រាប់បញ្ជាប្រព័ន្ធបណ្តាញដែលកំពុង

មានសព្វថ្ងៃ ។ អគ្គិសនីកម្ពុជាមានផែនការសាងសង់មជ្ឈមណ្ឌលបញ្ជាជាតិមួយនៅក្នុងអនុស្ថានីយខាងលិច ភ្នំពេញ ជាមួយនិងការសាងសង់ខ្សែបណ្តាញបញ្ជូនតង់ស្យុង ២៣០ គីឡូវ៉ុល ពីប្រទេសវៀតណាម មកភ្នំពេញ ។ មជ្ឈមណ្ឌលបញ្ជាមួយទៀតក៏ត្រូវសាងសង់នៅបន្ទាយមានជ័យ ឬសៀមរាប ដើម្បីបញ្ជាប្រព័ន្ធបណ្តាញបញ្ជូនដែលត្រូវសាងសង់ភ្ជាប់ពីប្រទេសថៃ ។ មជ្ឈមណ្ឌលបញ្ជាដូចគ្នានេះក៏ត្រូវសាងសង់សម្រាប់ប្រព័ន្ធបញ្ជូនទោលដទៃផ្សេងទៀតដែលត្រូវអភិវឌ្ឍដែរ ។ នៅពេលប្រព័ន្ធបណ្តាញបញ្ជូនទោលភ្ជាប់ចូលគ្នា មជ្ឈមណ្ឌលបញ្ជាដែលមានស្រាប់អាចត្រូវលុបចោល ឬក៏បន្តទៅទៀត ប៉ុន្តែជាចុងក្រោយ នឹងមានប្រព័ន្ធមួយដែលមានមជ្ឈមណ្ឌលបញ្ជាជាតិមួយ និងមជ្ឈមណ្ឌលបញ្ជាតាមតំបន់មួយចំនួន ។ ទីតាំង និងចំនួនមជ្ឈមណ្ឌលបញ្ជាតាមតំបន់អាស្រ័យនឹងទំហំនៃប្រព័ន្ធបណ្តាញបញ្ជូន និងភាពងាយស្រួលនៃដំណើរការបញ្ជា ។

## ឈ-អាជ្ញាប័ណ្ណនិងច្បាប់ស្តីពីអគ្គិសនី

មាត្រា ៣៨ របស់ច្បាប់ស្តីពីអគ្គិសនីចែងថា គោលនយោបាយរបស់រាជរដ្ឋាភិបាលគឺ :

១-កាត់បន្ថយការចំណាយម៉ាហ្ស៊ីណាល់សម្រាប់រយៈពេលវែងលើការផ្គត់ផ្គង់អគ្គិសនីជូនអ្នកប្រើប្រាស់

២-បង្កើតបណ្តាញជាតិបញ្ជូនអគ្គិសនី និងពង្រីកបណ្តាញនេះឱ្យបានទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៥ របស់ច្បាប់ស្តីពីអគ្គិសនីកំណត់ថា ក្នុងពេលសម្រេចចេញអាជ្ញាប័ណ្ណ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវយកចិត្តទុកដាក់លើ :

១-គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាលលើវិស័យអគ្គិសនី ក្នុងគោលបំណងកាត់បន្ថយការចំណាយម៉ាហ្ស៊ីណាល់រយៈពេលវែងនិងខ្លី

២-ការធានាផលប្រយោជន៍សាធារណៈ

៣-សេចក្តីសម្រេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដូចខ្លឹមសារចែងក្នុងមាត្រា ៤ ។

**មាត្រា ៣៨.-**

ក្នុងការចេញអាជ្ញាប័ណ្ណរួម អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវយកចិត្តទុកដាក់ចំពោះផែនការសម្រាប់រយៈពេលវែង ព្រមទាំងគោលដៅនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយការចំណាយម៉ាហ្ស៊ីណាល់សម្រាប់ដំណើរការរយៈពេលវែងលើការផ្គត់ផ្គង់អគ្គិសនីជូនអ្នកប្រើប្រាស់ ការបង្កើតបណ្តាញជាតិបញ្ជូនអគ្គិសនីនិង ការពង្រីកបណ្តាញនោះនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥..**

អ្នកផ្គត់ផ្គង់សេវាកម្មអគ្គិសនីនីមួយៗ ត្រូវមានអាជ្ញាប័ណ្ណដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ហើយត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់នេះ និងរាល់បញ្ញត្តិដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន ព្រមទាំងបទប្បញ្ញត្តិនិងនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងការតម្រូវតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

រាល់ការសម្រេចចេញអាជ្ញាប័ណ្ណត្រូវផ្អែកលើគោលនយោបាយ យុទ្ធសាស្ត្រនិង ផែនការលើវិស័យអគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានគោលបំណងកាត់បន្ថយចំណាយម៉ាហ្សីណាល់រយៈពេលវែងនិងខ្លីឱ្យបានតិចបំផុត ក្នុងការផ្គត់ផ្គង់អគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងសេចក្តីសម្រេចនានាដូចមានចែងក្នុងមាត្រា ៤ ហើយត្រូវធានាដល់ផលប្រយោជន៍សាធារណៈ ។

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាឱ្យអ្នកកាន់អាជ្ញាប័ណ្ណប្រតិបត្តិតាមស្តង់ដា ទាក់ទងទៅនឹងកិច្ចប្រតិបត្តិការបច្ចេកទេស សុវត្ថិភាព និងបរិស្ថានដែលបង្កើតឡើង និងផ្សព្វផ្សាយដោយក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

អាជ្ញាប័ណ្ណក្នុងច្បាប់នេះ សំដៅលើលិខិតអនុញ្ញាតដើម្បីធ្វើសេវាកម្មអគ្គិសនី ។

អ្នកកាន់អាជ្ញាប័ណ្ណក្នុងច្បាប់នេះ សំដៅលើបុគ្គលដែលកាន់កាប់អាជ្ញាប័ណ្ណ ស្របច្បាប់និងមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

មាត្រា ៤១ នៃច្បាប់អគ្គិសនីចែងថា ប្រសិនបើគ្មានអាជ្ញាប័ណ្ណ សកម្មភាពដូចខាងក្រោម ពុំអាចអនុវត្តបានឡើយ :

១-ដំណើរការជាក្រុមហ៊ុនសេវាកម្មអគ្គិសនី

២-ផ្តល់សេវាអគ្គិសនី

៣-អាជ្ញាប័ណ្ណត្រូវចេញឱ្យចំពោះតែបុគ្គលដែលមានសមត្ថភាពសមស្រប

នេះមានន័យថា អាជ្ញាប័ណ្ណមិនតម្រូវសម្រាប់អ្នកប្រើប្រាស់អគ្គិសនី ឬ អ្នកដំណើរការមធ្យោបាយអគ្គិសនីសម្រាប់តែការប្រើប្រាស់ផ្ទាល់ខ្លួនទេ ។ មុនពេលចេញអាជ្ញាប័ណ្ណឱ្យបុគ្គលណាមួយ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតែប្រាកដថា បុគ្គលនោះអាចបំពេញកាតព្វកិច្ច និងល័ក្ខខ័ណ្ឌសេវាកម្មដែលមានចែងក្នុងអាជ្ញាប័ណ្ណ ។

**មាត្រា ៤១.-**

គ្មានបុគ្គលណាមួយអាចដំណើរការជាក្រុមហ៊ុនសេវាកម្មអគ្គិសនី ឬផ្តល់សេវាកម្មអគ្គិសនីបានឡើយ លើកលែងតែបានអនុវត្តស្របតាមខ្លឹមសារនៃអាជ្ញាប័ណ្ណ ដែលមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

អាជ្ញាប័ណ្ណត្រូវបានចេញឱ្យចំពោះតែបុគ្គលណាដែលមានសមត្ថភាពសមស្របទៅនឹងតម្រូវការរបស់អាជ្ញាធរអគ្គិសនីកម្ពុជាដើម្បីដំណើរការជាក្រុមហ៊ុនសេវាកម្មអគ្គិសនី និង ដើម្បីបំពេញកាតព្វកិច្ច និង លក្ខខ័ណ្ឌសេវាកម្មដែលមានចែងអាជ្ញាប័ណ្ណ ។

មិនត្រូវទាមទារឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្តល់សេវាកម្មអគ្គិសនី ដែលមានថ្លៃទាបជាងបញ្ជីថ្លៃលក់អគ្គិសនីនោះទេ លើកលែងតែអ្នកប្រើប្រាស់នោះបានទទួលការជួយឧបត្ថម្ភពីមូលនិធិពិសេសណាមួយ ហើយអ្នកកាន់អាជ្ញាប័ណ្ណក៏មានការឯកភាពទៅលើការចាត់ចែងនោះដែរ ។

មាត្រា ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីចែងថា អាជ្ញាប័ណ្ណរួមអាចជាអាជ្ញាប័ណ្ណមួយដែលរួមបញ្ចូលអាជ្ញាប័ណ្ណមួយចំនួន ឬទាំងអស់ (អាជ្ញាប័ណ្ណផលិតកម្ម បញ្ជូន បែងចែក ចែកចាយ លក់ដុំ លក់រាយ សេវាកម្មបន្ត) ។ មាត្រាទាំង២គឺ ៣៥ និង៣៨ ចែងអំពីករណីទាំងឡាយដែលអាចផ្តល់អាជ្ញាប័ណ្ណរួម ប៉ុន្តែមិនមានបញ្ញត្តិហាមឃាត់មិនឱ្យចេញអាជ្ញាប័ណ្ណរួមឡើយ មានន័យថា ពុំមានចែងថាអំពីករណីដែលមិនអាចចេញអាជ្ញាប័ណ្ណរួមឡើយ ។ យោងតាមខ្លឹមសារមាត្រាទាំងពីរនេះ អាជ្ញាប័ណ្ណរួមអាចចេញឱ្យ :

១-អគ្គិសនីកម្ពុជា

២-ប្រព័ន្ធទោល

៣-សម្រាប់ការបង្កើតប្រព័ន្ធបណ្តាញបញ្ជូនជាតិ និងការពង្រីកបណ្តាញនេះជាបន្តបន្ទាប់

៤-ដើម្បីកាត់បន្ថយចំណាយម៉ាហ្ស៊ីណាល់សម្រាប់ដំណើរការរយៈពេលវែងលើការផ្គត់ផ្គង់អគ្គិសនីជូនអ្នកប្រើប្រាស់

៥-ធានាផលប្រយោជន៍សាធារណៈ

**មាត្រា ៣៥.-**

អាជ្ញាប័ណ្ណរួមជាប្រភេទអាជ្ញាប័ណ្ណមួយ ដែលរួមបញ្ចូលអាជ្ញាប័ណ្ណមួយចំនួនឬទាំងអស់ដូចមានចែងក្នុងកថាខ័ណ្ឌ ១ ដល់កថាខ័ណ្ឌ ៧ នៃមាត្រា ២៩ នៃច្បាប់នេះ។

អាជ្ញាប័ណ្ណរួមអាចចេញឱ្យអគ្គិសនីកម្ពុជានិងប្រព័ន្ធទោល ដើម្បីផ្តល់សិទ្ធិឱ្យផលិត បញ្ជូន បែងចែក ចែកចាយនិងលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ។ ក្នុងករណីបន្ថែមមធ្យោបាយផលិតកម្មអគ្គិសនីថ្មីនីមួយៗ អ្នកកាន់អាជ្ញាប័ណ្ណរួមត្រូវសុំអាជ្ញាប័ណ្ណផលិតកម្មថែមទៀត ។

ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងការប្រកួតប្រជែងដែលនឹងធ្វើឱ្យការចំណាយមាំហ្សីណាល់សម្រាប់ដំណើរការរយៈពេលវែងចុះទាបបំផុត អាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវដាក់ល័ក្ខខ័ណ្ឌឱ្យបំបែកសេវាកម្មផលិតកម្ម សេវាកម្មបញ្ជូន និង សេវាកម្មចែកចាយអគ្គិសនីចេញពីគ្នា ក្នុងតំបន់សេវាកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ ។

មាត្រា ៤០ នៃច្បាប់អគ្គិសនីបានចែងថា សម្រាប់ការចេញអាជ្ញាប័ណ្ណសេវាកម្មបន្តដើម្បីធ្វើសេវាកម្មបន្តយោងទៅតាមកិច្ចសន្យាសេវាកម្មបន្តជាមួយអ្នកកំពុងកាន់អាជ្ញាប័ណ្ណ ។ ដូច្នេះ យោងតាមមាត្រានេះ នឹងត្រូវមានអាជ្ញាប័ណ្ណពីរដែលមានសិទ្ធិផ្តល់សេវាកម្មអគ្គិសនីដូចគ្នា មួយគឺអ្នកកំពុងកាន់អាជ្ញាប័ណ្ណ ឬអ្នកកាន់អាជ្ញាប័ណ្ណមេ និងពីរគឺអ្នកកាន់អាជ្ញាប័ណ្ណសេវាកម្មបន្តដែលបានត្រូវចុះកិច្ចសន្យាសេវាកម្មបន្តជាមួយអ្នកកាន់អាជ្ញាប័ណ្ណមេដើម្បីធ្វើសេវាកម្ម ។ កិច្ចសន្យាសេវាកម្មបន្តអាចគ្របដណ្តប់សេវាកម្មទាំងអស់ ឬមួយផ្នែករបស់អ្នកកាន់អាជ្ញាប័ណ្ណ ក្រោមអាជ្ញាប័ណ្ណរបស់ខ្លួន ។ ដោយគ្រាន់តែបានចុះហត្ថលេខាលើកិច្ចសន្យាសេវាកម្មបន្តបុគ្គលទី២ មិនអាចផ្តល់សេវាកម្មបានទេ ។ បុគ្គលទី២នេះអាចផ្តល់សេវាកម្មបានលុះត្រាតែខ្លួន មានអាជ្ញាប័ណ្ណសេវាកម្មបន្តបន្ថែមទៀត ។ មាត្រា ៤៥ ចែងថា អ្នកកាន់អាជ្ញាប័ណ្ណអាចបោះបង់ ឬផ្ទេរអាជ្ញាប័ណ្ណរបស់ខ្លួនឱ្យទៅបុគ្គលណាមួយបាន លុះត្រាតែមានការអនុញ្ញាតជាពិសេសពីអាជ្ញាធរអគ្គិសនីកម្ពុជា ។ ក្នុងអាជ្ញាប័ណ្ណសេវាកម្មបន្ត អ្នកកាន់អាជ្ញាប័ណ្ណមេ មិនមែនធ្វើការផ្ទេរអាជ្ញាប័ណ្ណទេ ។ អ្នកកាន់អាជ្ញាប័ណ្ណមេនៅរក្សាសិទ្ធិរបស់ខ្លួនដែលមានក្នុងអាជ្ញាប័ណ្ណដដែល ប៉ុន្តែអនុញ្ញាតឱ្យបុគ្គលមួយទៀតធ្វើសេវាកម្មដែលខ្លួនមានសិទ្ធិធ្វើ ។ បុគ្គលទី២នោះអាចធ្វើសេវាកម្មបាន លុះត្រាតែបានចុះកិច្ចសន្យាសេវាកម្មបន្ត និងមានអាជ្ញាប័ណ្ណសេវាកម្មបន្ត ។ ការចេញអាជ្ញាប័ណ្ណ និងការផ្តល់សិទ្ធិសម្រាប់ធ្វើសេវាកម្មដូចគ្នាសម្រាប់បុគ្គលទាំងពីរ មានទំនាក់ទំនងគ្នាដូចតទៅ :

(i) ក្នុងការចេញអាជ្ញាប័ណ្ណសេវាកម្មបន្ត សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណមេ មិនត្រូវបានដកចេញទេ សិទ្ធិអាជ្ញាប័ណ្ណសេវាកម្មបន្ត គឺជាសិទ្ធិបណ្តោះអាសន្ន ដូចបានកំណត់ក្នុងកិច្ចសន្យាសេវាកម្មបន្ត ដែលត្រូវអនុញ្ញាតឱ្យធ្វើការជំនួសដោយបុគ្គលទី២ ។ បន្ទាប់ពីកិច្ចសន្យាសេវាកម្មបន្តអស់សុពលភាព ឬត្រូវបានដកហូត ដោយសារអ្នកកាន់អាជ្ញាប័ណ្ណសេវាកម្មបន្តមិនអាចផ្តល់សេវាកម្មនោះបាន អ្នកកាន់អាជ្ញាប័ណ្ណមេត្រូវតែទទួលកាតព្វកិច្ចផ្តល់សេវាកម្មនោះ ។ ប្រសិនបើខ្លួនមិនអាចផ្តល់សេវាកម្មនោះទេ ត្រូវចាត់ទុកថា ខ្លួនបានរំលោភលើល័ក្ខខ័ណ្ឌអាជ្ញាប័ណ្ណ ។

(ii) ដើម្បីមានលទ្ធភាពអនុវត្តការងារខាងលើ អ្នកកាន់អាជ្ញាប័ណ្ណមេគួរតែមានមធ្យោបាយសម្រាប់ផ្តល់សេវាកម្ម ។ ប្រសិនបើ មធ្យោបាយធ្វើសេវាកម្មនោះជាកម្មសិទ្ធិរបស់អ្នកកាន់អាជ្ញាប័ណ្ណមេ ហើយអ្នកកាន់អាជ្ញាប័ណ្ណសេវាកម្មបន្តត្រូវបានអនុញ្ញាតឱ្យដំណើរការមធ្យោបាយធ្វើសេវាកម្មនោះ អ្នកកាន់អាជ្ញាប័ណ្ណមេក៏ត្រូវមានសិទ្ធិដំណើរការមធ្យោបាយធ្វើសេវាកម្មនោះដែរ ។ ប្រសិនបើមធ្យោបាយធ្វើសេវាកម្មមួយផ្នែកឬទាំងអស់ជាកម្មសិទ្ធិរបស់អ្នកកាន់អាជ្ញាប័ណ្ណសេវាកម្មបន្ត

កិច្ចសន្យាសេវាកម្មបន្តគួរកំណត់ល័ក្ខខ័ណ្ឌសម្រាប់អ្នកកាន់អាជ្ញាប័ណ្ណមេ មានលទ្ធភាពដំណើរការមធ្យោបាយធ្វើសេវាកម្មដែលកំពុងមាន ឬ មានលទ្ធភាពសាងសង់មធ្យោបាយធ្វើសេវាកម្មចាំបាច់នានា ។ នេះមានន័យថា កិច្ចសន្យាសេវាកម្មបន្ត គួរមានល័ក្ខខ័ណ្ឌដែលអាចឱ្យការផ្គត់ផ្គង់សេវាកម្មដំណើរការបានដោយគ្មានការរអាក់រអួលដែលមិនអាចដឹងជាមុន ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណសេវាកម្មបន្តមិនអាចផ្តល់សេវាកម្មបានដោយសារហេតុផលផ្សេងៗ ។ នៅពេលអនុញ្ញាតឱ្យចុះកិច្ចសន្យាសេវាកម្មបន្ត ឬចេញអាជ្ញាប័ណ្ណសេវាកម្មបន្ត អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាអំពីបញ្ហានេះ ។

**មាត្រា ៤០.-**

អ្នកកាន់អាជ្ញាប័ណ្ណសេវាកម្មបន្តមានសិទ្ធិផ្គត់ផ្គង់សេវាកម្មអគ្គិសនីស្របតាមកិច្ចសន្យាបន្តជាមួយអ្នកដែលមានអាជ្ញាប័ណ្ណស្រាប់ ។ អាជ្ញាប័ណ្ណស្របតាមមាត្រានេះ ត្រូវបញ្ចូលគ្រប់ល័ក្ខខ័ណ្ឌដែលអាចអនុវត្តបាន ព្រមទាំងល័ក្ខខ័ណ្ឌបន្ថែមនៃអាជ្ញាប័ណ្ណដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចសន្និដ្ឋានថា ស្ថិតក្នុងផលប្រយោជន៍សាធារណៈ ។

អាជ្ញាធរអគ្គិសនីកម្ពុជាចេញបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងសកម្មភាព និងកិច្ចប្រតិបត្តិការនៃកិច្ចសន្យាបន្តដែលអាជ្ញាធរអគ្គិសនីកម្ពុជាអាចសន្និដ្ឋានថា ស្ថិតក្នុងផលប្រយោជន៍សាធារណៈ ។

## ឈ.-អាជ្ញាប័ណ្ណបញ្ជូន

មាត្រា ៣១ ៣២ និង ៣៣ នៃច្បាប់អគ្គិសនីចែងអំពីអាជ្ញាប័ណ្ណបញ្ជូន ។ មាត្រា ៣១ ចែងថា អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនត្រូវមានសិទ្ធិដូចខាងក្រោម :

(i) សិទ្ធិជាម្ចាស់ សិទ្ធិដំណើរការ និងសិទ្ធិគ្រប់គ្រងលើមធ្យោបាយបញ្ជូនអគ្គិសនី

(ii) សិទ្ធិទទួលនិងបញ្ជូនអគ្គិសនី – ទទួលអគ្គិសនីពីអ្នកកាន់អាជ្ញាប័ណ្ណមួយផ្សេងទៀត បញ្ជូនវាតាមមធ្យោបាយធ្វើសេវាកម្មរបស់ខ្លួន និងផ្តល់វាឱ្យអ្នកដទៃមួយទៀត ។

(iii) លក់អគ្គិសនីដុំ – ផលិតឬទិញអគ្គិសនី បញ្ជូនវាតាមមធ្យោបាយធ្វើសេវាកម្មរបស់ខ្លួន ហើយលក់អគ្គិសនីក្នុងរូបភាពដុំឱ្យអ្នកកាន់អាជ្ញាប័ណ្ណមួយផ្សេងទៀត ឬអ្នកប្រើប្រាស់ដុំ ។

មាត្រា ៣១ ចែងអំពីអាជ្ញាប័ណ្ណបញ្ជូនពីរប្រភេទ (១) អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី និង (២) អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។ មាត្រា ៣២ បញ្ជាក់អំពីអាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី និង មាត្រា ៣៣ បញ្ជាក់អំពីអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។ អាជ្ញាប័ណ្ណទាំងពីរ ចែងអំពីសិទ្ធិដូចគ្នារបស់អ្នកកាន់អាជ្ញាប័ណ្ណ ដូចបានរៀបរាប់ខាងលើ ក្នុងមាត្រា ៣១ ។ ប៉ុន្តែអាជ្ញាប័ណ្ណទាំងពីរ មានល័ក្ខខ័ណ្ឌខុសគ្នា សម្រាប់ទិដ្ឋភាពដូចតទៅ :

(i) អ្នកកាន់អាជ្ញាប័ណ្ណ – អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ត្រូវបានផ្តល់ឱ្យតែក្រុមហ៊ុនធ្វើសេវាកម្មបញ្ជូនអគ្គិសនីមួយដែលរដ្ឋទទួលខុសត្រូវ (ក្រុមហ៊ុនអគ្គិសនីកម្ពុជាបច្ចុប្បន្ន) ។ ដូច្នេះ អាចមានអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីតែមួយគត់ ។ អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស អាចត្រូវបានចេញឱ្យក្រុមហ៊ុនណាមួយដែលមានសិទ្ធិ (ក្រុមហ៊ុនរដ្ឋ ក្រុមហ៊ុនចម្រុះ ឬ ក្រុមហ៊ុនឯកជន) ក្រៅពីក្រុមហ៊ុនធ្វើសេវាកម្មបញ្ជូនអគ្គិសនីមួយដែលរដ្ឋទទួលខុសត្រូវ ។ ដូច្នេះ អាចមានអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសច្រើនលើសពីមួយ ។

(ii) តំបន់អនុញ្ញាតឱ្យធ្វើប្រតិបត្តិការ – អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីមានសិទ្ធិធ្វើសេវាកម្មបញ្ជូនអគ្គិសនីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា (លើកលែងតែកន្លែងជាសិទ្ធិរបស់អ្នកអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស) ដោយឡែកអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស មានសិទ្ធិធ្វើសេវាកម្មបញ្ជូនត្រឹមតែលើមធ្យោបាយធ្វើសេវាកម្មដែលកំណត់ជាពិសេសក្នុងអាជ្ញាប័ណ្ណ ។ អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី **បញ្ជាក់ពីតំបន់ប្រតិបត្តិការ** ដូច្នេះ អ្នកកាន់អាជ្ញាប័ណ្ណអាចសាងសង់និងដំណើរការមធ្យោបាយធ្វើសេវាកម្មបញ្ជូនដែលចាំបាច់ក្នុងតំបន់អនុញ្ញាត ។ ប៉ុន្តែ អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសបញ្ជាក់ពី**មធ្យោបាយធ្វើសេវាកម្មបញ្ជូន ។** ដូច្នេះ ការដំណើរការនៅក្រោមអាជ្ញាប័ណ្ណនេះ គឺត្រូវបានកំណត់ព្រំដែនត្រឹមត្រូវលើមធ្យោបាយធ្វើសេវាកម្មជាក់លាក់ ហើយមិនអាចដំណើរការមធ្យោបាយធ្វើសេវាកម្មដទៃទៀត ដែលមិនមានកំណត់ក្នុងអាជ្ញាប័ណ្ណបានឡើយ ។

(iii) អាណត្តិអាជ្ញាប័ណ្ណ – អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី អាចមានអាណត្តិមួយមិនកំណត់ ដូចនៅទីតាំងដែលអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស អាចមានអាណត្តិមិនកំណត់ ឬមានកម្រិតត្រឹមអាយុកាលនៃមធ្យោបាយធ្វើសេវាកម្មដែលមានក្នុងអាជ្ញាប័ណ្ណ ។

ក្នុងនាមជាអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ដែលត្រូវបានផ្តល់សិទ្ធិឱ្យធ្វើសេវាកម្មបញ្ជូនអគ្គិសនីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយក៏មានចែងលក្ខខ័ណ្ឌសម្រាប់ចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសផងដែរ គេគិតថា អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី នឹងក្លាយទៅជាអ្នកផ្តល់សេវាកម្មបញ្ជូនអគ្គិសនីចំបង ប៉ុន្តែ មិនមែនជាអ្នកផ្តល់សេវាកម្មតែម្នាក់ឯងនោះទេ ។ ករណីអាចកើតថា មានដែលអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីមិនអាចសាងសង់មធ្យោបាយធ្វើសេវាកម្មបញ្ជូនខ្លះបាន ដោយសារមិនមានទុនគ្រប់គ្រាន់ ឬ ដោយសារការសាងសង់នេះមិនមែនជាគម្រោងអាទិភាពខ្ពស់សម្រាប់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ប៉ុន្តែ ជាគម្រោងមានអាទិភាពខ្ពស់ជាងសម្រាប់សហគ្រិនមួយចំនួនផ្សេងទៀត ។ ឧទាហរណ៍ដែលអាចកើតមានចំពោះគម្រោងដែលមិនមានអាទិភាពខ្ពស់ចំពោះអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនជាតិ អាចមានដូចខាងក្រោម :

(i) ខ្សែបណ្ដាញបញ្ជូនភ្ជាប់ប្រទេសជាច្រើនឆ្លងកាត់ប្រទេសកម្ពុជា ប៉ុន្តែ មិនបានភ្ជាប់ជាមួយហេដ្ឋារចនាសម្ព័ន្ធរបស់កម្ពុជា

(ii) មធ្យោបាយធ្វើសេវាកម្មបញ្ជូនអគ្គិសនីមួយសម្រាប់បញ្ជូនអគ្គិសនីពីរោងចក្រផលិតអគ្គិសនីធំមួយនៅប្រទេសកម្ពុជា ទៅប្រទេសជិតខាងមួយ

(iii) មធ្យោបាយធ្វើសេវាកម្មបញ្ជូនអគ្គិសនីមួយដែលមិនភ្ជាប់ទៅនឹងខ្សែណ្ដាញមេ

(iv) ក្នុងករណីខ្លះ សហគ្រិនមួយផ្សេងទៀតអាចមានភាពងាយស្រួលជាងក្នុងការរកទុនដើម្បីសាងសង់ និងដំណើរការមធ្យោបាយបញ្ជូនអគ្គិសនីខ្លះ ។

**មាត្រា ៣១.-**

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនមានសិទ្ធិធ្វើសេវាកម្មបញ្ជូនអគ្គិសនី ។ សិទ្ធិធ្វើសេវាកម្មបញ្ជូនអគ្គិសនីក្នុងច្បាប់នេះ គឺសិទ្ធិជាម្ចាស់ សិទ្ធិដំណើរការ និងសិទ្ធិគ្រប់គ្រងលើមធ្យោបាយបញ្ជូនអគ្គិសនីដើម្បីផ្ទេរប្រគល់ ឬលក់អគ្គិសនីក្នុងបរិមាណធំ ។

អាជ្ញាប័ណ្ណបញ្ជូនមានពីរប្រភេទគឺអាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនី និងអាជ្ញាប័ណ្ណបញ្ជូនសំរាប់គោលបំណងពិសេស ។

**មាត្រា ៣២.-**

អាជ្ញាប័ណ្ណបញ្ជូនសំរាប់បណ្ដាញជាតិបញ្ជូនអគ្គិសនី ត្រូវបានផ្ដល់ឱ្យអ្នកធ្វើសេវាកម្មបញ្ជូនអគ្គិសនីមួយ ដែលរដ្ឋទទួលខុសត្រូវ ហើយមានសិទ្ធិសម្រាប់ធ្វើការបញ្ជូនអគ្គិសនីដល់ក្រុមហ៊ុនចែកចាយអគ្គិសនី និងដល់អ្នកប្រើប្រាស់ធំៗក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែក្នុងតំបន់ប្រើប្រាស់ប្រព័ន្ធទោលដូចមានចែងក្នុងវាក្យខ័ណ្ឌ ១ នៃមាត្រា ៣៥ និងលើកលែងតែក្នុងករណីមានការផ្ដល់សិទ្ធិដោយឡែកឱ្យអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនក្នុងគោលបំណងពិសេស ដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ ។

អាជ្ញាប័ណ្ណដែលបានចេញស្របតាមមាត្រានេះ អាចមានអាណត្តិមួយមិនកំណត់ និងអាចដកហូតបានស្របតាមច្បាប់នេះ ។

**មាត្រា ៣៣.–**

អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសមានសិទ្ធិសាងសង់ ធ្វើជាម្ចាស់ និង/ឬ ដំណើរការលើមធ្យោបាយបញ្ជូនអគ្គិសនីដែលបានកំណត់ជាក់លាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានគោលដៅច្បាស់លាស់និងធានាដល់ផលប្រយោជន៍សាធារណៈ ។ គោលការណ៍និងល័ក្ខខ័ណ្ឌសម្រាប់ការផ្តល់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ត្រូវកំណត់ដោយបញ្ញត្តិរបស់រាជរដ្ឋាភិបាល ។

សុពលភាពនៃអាជ្ញាប័ណ្ណបញ្ជូនសំរាប់គោលបំណងពិសេស អាចមានរយៈពេលមួយមិនកំណត់ ឬមានកំរិតត្រឹមអាយុកាលប្រើប្រាស់ដោយប្រសិទ្ធភាពនៃមធ្យោបាយបញ្ជូននោះ ។ អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស អាចដកហូតបានតាមបញ្ញត្តិនៃច្បាប់នេះ ។

## ៧.–គោលការណ៍និងល័ក្ខខ័ណ្ឌសម្រាប់ចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស

ច្បាប់អគ្គិសនី មិនបានកំណត់ព្រំដែនតឹងរឹងណាមួយលើការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសទេ ។ ប៉ុន្តែមាត្រា ៣៣ នៃច្បាប់ស្តីពីអគ្គិសនីចែងថា គោលការណ៍និងល័ក្ខខ័ណ្ឌសម្រាប់ការផ្តល់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ត្រូវកំណត់ដោយបញ្ញត្តិរបស់រាជរដ្ឋាភិបាល ។

ការកំណត់របស់ច្បាប់ថា គោលការណ៍និងល័ក្ខខ័ណ្ឌនេះត្រូវកំណត់ដោយ **បញ្ញត្តិរបស់រាជរដ្ឋាភិបាល** គឺពុំបានប្រើពាក្យថាត្រូវកំណត់ដោយ **អនុក្រឹត្យ** ដូចក្នុងករណីកំណត់កំរែអាជ្ញាប័ណ្ណដែលមានចែងក្នុងមាត្រា ២៧ និងក្នុងករណីចេញគោលការណ៍កំណត់ភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនីចែងក្នុងមាត្រា ៤៨ ។ នេះគឺមានន័យថា ការកំណត់នេះអាចធ្វើដោយលិខិតបទដ្ឋានដែលមានកម្រិតទាបជាងអនុក្រឹត្យ ។ ដោយសារថាបញ្ហានេះគឺជាបញ្ហាបច្ចេកទេស ដូច្នេះហើយ គោលការណ៍និងល័ក្ខខ័ណ្ឌនេះអាចត្រូវកំណត់**ដោយប្រកាសរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** ដូចក្នុងករណីកំណត់ស្តង់ដាបច្ចេកទេសអគ្គិសនីដែរ ។

ការកំណត់នេះអនុញ្ញាតឱ្យមានភាពបត់បែននិងលទ្ធភាព ដើម្បីតម្រូវទៅតាមស្ថានភាពប្រែប្រួលនៅក្នុងការវិវត្តន៍របស់ប្រព័ន្ធ ។ គោលការណ៍និងល័ក្ខខ័ណ្ឌសម្រាប់ការផ្តល់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសអាចធ្វើការកែសម្រួលដោយរាជរដ្ឋាភិបាល ដោយកែសម្រួលប្រកាសនៅពេលមានតម្រូវការចាំបាច់ ។

ដូចបានពិភាក្សាក្នុងផ្នែកទី១ ច្បាប់ស្តីពីអគ្គិសនីបានកំណត់គោលការណ៍ដូចខាងក្រោមសម្រាប់ការចេញអាជ្ញាប័ណ្ណ ហើយដែលត្រូវតែគោរពផងដែរក្នុងការផ្តល់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស :

១– ត្រូវកាត់បន្ថយចំណាយម៉ាហ្ស៊ីណាល់សម្រាប់ដំណើរការរយៈពេលវែង លើការផ្គត់ផ្គង់អគ្គិសនីជូនអ្នកប្រើប្រាស់

២– ត្រូវបង្កើតប្រព័ន្ធបណ្តាញបញ្ជូនជាតិ និងការពង្រីកបណ្តាញនេះជាបន្តបន្ទាប់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

៣– ត្រូវធានាផលប្រយោជន៍សាធារណៈ

៤–សេចក្តីសម្រេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល លើខ្លឹមសារដែលកំណត់ក្នុងមាត្រា ៤

ក្រៅពីគោលការណ៍ខាងលើ ត្រូវមានគោលការណ៍បន្ថែមមួយចំនួនសម្រាប់ការផ្តល់អាជ្ញាប័ណ្ណបញ្ជូនសំរាប់គោលបំណងពិសេស ដូចខាងក្រោម ៖

**១–អាជ្ញាធរអគ្គិសនីកម្ពុជា គួរពិនិត្យអំពីអត្ថប្រយោជន៍នៃមធ្យោបាយបញ្ជូនអគ្គិសនី និងពេលវេលាដែលត្រូវការមធ្យោបាយបញ្ជូននោះ មុនពេលផ្តល់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសសម្រាប់មធ្យោបាយធ្វើសេវាកម្មដែលស្នើសុំ**

នៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍ប្រព័ន្ធបណ្តាញបញ្ជូនរង និងប្រព័ន្ធបណ្តាញបញ្ជូនច្រើនតែជាខ្សែដែលមានទិសដៅតែមួយ ទោះជាមានខ្សែស្របទិសដៅក៏ដោយ ក៏បណ្តាញនេះច្រើនតែជាបណ្តាញសាមញ្ញ ។ ដូច្នេះ គេអាចប៉ាន់ប្រមាណមើលបានយ៉ាងស្រួលនូវអត្ថប្រយោជន៍នៃហេដ្ឋារចនាសម្ព័ន្ធថ្មី និងឥទ្ធិពលរបស់វាលើបណ្តាញកំពុងដំណើរការ ។ ខណៈពេលដែលប្រព័ន្ធបណ្តាញបញ្ជូនពង្រីកខ្លួននិងខណៈពេលដែលខ្សែបណ្តាញជាច្រើនត្រូវបានបន្ថែម ពេលនោះខ្សែស្របទិសដៅជាច្រើននឹងត្រូវបង្កើតឡើង ដែលចាំបាច់ត្រូវធ្វើការសិក្សាលម្អិតនិងស៊ីជម្រៅទើបដឹងអំពីអត្ថប្រយោជន៍ អំពីមធ្យោបាយថ្មី និងឥទ្ធិពលរបស់វាលើបណ្តាញដែលកំពុងដំណើរការ ។ ជាធម្មតាការសិក្សានេះត្រូវធ្វើដោយកុំព្យូទ័រនិងប្រើប្រាស់កម្មវិធីសមស្របមួយ ។

ការសិក្សាលម្អិតនេះអាចបញ្ចូលមួយចំនួនឬទាំងអស់នូវការសិក្សាទាំងឡាយ ដូចខាងក្រោម ៖

–ការសិក្សាលំហូរនៃបន្ទុក

–ការសិក្សាអំពីក្ងួរសៀគ្វី

–ការសិក្សាអំពីលំនឹងក្នុងរយៈពេលខ្លី

–ការវិភាគអំពីលំនឹងអចិន្ត្រៃយ៍

–ការវិភាគអំពីលំនឹងតង់ស្យុង

–ការវិភាគអំពីអេឡិចត្រូម៉ាញ៉េទិចរយៈពេលខ្លី

–ការវិភាគអំពីស្ថិរភាព

ការសិក្សាទាំងនេះត្រូវធ្វើនៅពេលធ្វើផែនការខ្សែបណ្តាញ ។ ដូច្នេះ ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធមួយបានបញ្ចូលទៅក្នុងផែនការអត្ថប្រយោជន៍ និងឥទ្ធិពលរបស់វាលើបណ្តាញអាចត្រូវដឹងបាននៅក្នុងឯកសារសិក្សាផែនការនោះ ។ ទោះជាយ៉ាងណាក៏ដោយ ត្រូវតែធានាថា ការសិក្សាផែនការត្រូវតែឈរលើមូលដ្ឋាននៃទិន្នន័យថ្មី ។ ប្រសិនបើទិន្នន័យដែលជាមូលដ្ឋាននៃការសិក្សាមុនមានការប្រែប្រួល ចាំបាច់ត្រូវធ្វើការសិក្សាជាថ្មីឡើងវិញ ។ នៅក្នុងការសិក្សា គេត្រូវការចាំបាច់នូវទិន្នន័យសិក្សាសម្រាប់ខ្សែបណ្តាញកំពុងដំណើរការនិងខ្សែបណ្តាញថ្មី សម្រាប់ផលិតកម្ម និងសម្រាប់ការប៉ាន់ស្មានបន្ទុកលំអិត ។ល។ អគ្គិសនីកម្ពុជាដែលជាអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញបញ្ជូនជាតិអគ្គិសនី អាចមានភាពងាយស្រួលក្នុងការអនុវត្តន៍

ការសិក្សានេះ ពីព្រោះជាការសិក្សាបច្ចេកទេសតាមលក្ខណៈរបស់វា ហើយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចប្រើប្រាស់លទ្ធផលនៃការសិក្សានេះសម្រាប់ធ្វើផែនការក្នុងវិស័យអគ្គិសនី ។ ប្រសិនបើការសិក្សានេះទាមទារឱ្យមានការពិនិត្យលទ្ធភាពនៃមធ្យោបាយធ្វើសេវាកម្មថ្មី ដែលស្នើឡើងដោយបុគ្គលមួយផ្សេងទៀត ដែលមិនមែនជាអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនី ហើយមិនមាននៅក្នុងការសិក្សាដែលមានស្រាប់ ការចំណាយសម្រាប់ធ្វើការសិក្សាបន្ថែមទាំងនេះអាចជាបន្ទុករបស់ស្ថាប័នពាក់ព័ន្ធ ឬ ត្រូវសម្រេចដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬ អគ្គិសនីកម្ពុជា ។

សម្រាប់អាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីអាចទទួលយកបាននូវសេចក្ដីត្រូវការនៃមធ្យោបាយដែលស្នើឡើងនេះ ពាក្យស្នើសុំអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសត្រូវតែមានភ្ជាប់នូវការពន្យល់អំពីអត្ថប្រយោជន៍នៃមធ្យោបាយធ្វើសេវាកម្មដែលស្នើឡើងនោះ ។ ប្រសិនបើនៅពេលស្នើសុំ ប្រព័ន្ធបណ្ដាញមានការអភិវឌ្ឍន៍ខុសមុនបន្តិច ហើយអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថា ត្រូវតែធ្វើការសិក្សាឡើងវិញដើម្បីឱ្យដឹងអត្ថប្រយោជន៍នៃមធ្យោបាយធ្វើសេវាកម្មតង់ស្យុងខ្ពស់ អាជ្ញាធរអគ្គិសនីកម្ពុជាអាចតម្រូវឱ្យពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយនូវលទ្ធផលនៃការសិក្សាដែលបង្ហាញថា ហេដ្ឋារចនាសម្ព័ន្ធនេះ ពិតជាត្រូវការចាំបាច់ព្រមទាំងពេលវេលាដែលវាត្រូវការ ឬ ផែនការនិងឯកសារយោងលម្អិតដែលមានបង្ហាញថា ហេដ្ឋារចនាសម្ព័ន្ធនេះមានបញ្ចូលនៅក្នុងផែនការ ។

## ២-អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនី ជាអ្នកមានសិទ្ធិទីមួយ ក្នុងការសាងសង់មធ្យោបាយបញ្ជូនដែលស្នើសុំ ក្នុងរយៈពេលដែលមធ្យោបាយនេះត្រូវការ

អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតែជឿជាក់ខ្លួនឯងផ្ទាល់ថា អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនីមិនមានបំណងសាងសង់មធ្យោបាយបញ្ជូននៅក្នុងរយៈពេលដែលត្រូវការមធ្យោបាយនេះឡើយ មុនពេលផ្ដល់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។ ការងារនេះអាចអនុវត្តបានដោយអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធ្វើលិខិតទៅអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនី ឬទៅអ្នកស្នើសុំ ដើម្បីឱ្យមានលិខិតចាំបាច់នានា ពីអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនី ហើយដាក់ឯកសារទាំងនោះជាមួយពាក្យសុំ ដើម្បីស្នើសុំអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។ អាជ្ញាធរអគ្គិសនីកម្ពុជាអាចពិគ្រោះយោបល់ជាមួយ អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនីសម្រាប់ការចេញអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។ ប្រសិនបើ អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនីផ្ដល់ដំណឹងថា គេស្នើសុំសាងសង់មធ្យោបាយបញ្ជូនក្នុងរយៈពេលដែលគេត្រូវការ ហើយអ្នកស្នើសុំជំទាស់នឹងបញ្ហានេះ ពេលនោះអ្នកស្នើសុំអាចធ្វើការតវ៉ាមកអាជ្ញាធរអគ្គិសនីកម្ពុជា ហើយអាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការស៊ើបអង្កេតអំពីបញ្ហានោះ ។

ដូចបានពិភាក្សាមុននេះ ការធ្វើផែនការ និងការដំណើរការប្រព័ន្ធបណ្ដាញបញ្ជូន ទាមទារឱ្យមានការសម្របសម្រួលគ្នាក្នុងកម្រិតមួយ ។ ដើម្បីធានាការសម្របសម្រួលគ្នានេះ អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ត្រូវមានល័ក្ខខ័ណ្ឌអាជ្ញាប័ណ្ណបន្ថែម ថែមពីលើល័ក្ខខ័ណ្ឌធម្មតារបស់អាជ្ញាប័ណ្ណ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ក្នុងប្រភេទអាជ្ញាប័ណ្ណផ្សេងៗ ។ ល័ក្ខខ័ណ្ឌបន្ថែមមានដូចខាងក្រោម :

**១-គោរពតាមកូដប្រព័ន្ធបណ្តាញ –** កូដប្រព័ន្ធបណ្តាញគឺជាច្បាប់បច្ចេកទេស ដែលមានសារៈសំខាន់បំផុត សម្រាប់ការដំណើរការប្រព័ន្ធបណ្តាញឱ្យបានត្រឹមត្រូវ ។ កូដប្រព័ន្ធបណ្តាញត្រូវតែគ្របដណ្តប់លើការធ្វើផែនការប្រព័ន្ធ ល័ក្ខខ័ណ្ឌតភ្ជាប់ នីតិវិធីនៃការដំណើរការបណ្តាញ កម្មវិធីការងារ និងបញ្ហាការបែងចែក ផែនការផ្តាច់ចរន្ត ការកត់ត្រាទិន្នន័យ និងការផ្តល់ពត៌មាន ។ល។ អ្នកកាន់អាជ្ញាប័ណ្ណផលិតកម្ម និងអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនទាំងអស់ត្រូវតែអនុវត្តតាមកូដប្រព័ន្ធបណ្តាញនេះ ។

**២-ការផ្តល់ពីមធ្យោបាយគមនាគមន៍ –** អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្តល់នូវមធ្យោបាយគមនាគមន៍សមស្រប (ដូចជាប្រព័ន្ធ SCADA) និង ឧបករណ៍វាស់វែងនានាដែលត្រូវតែត្រូវគ្នាជាមួយមធ្យោបាយបានផ្តល់នៅក្នុងមជ្ឈមណ្ឌលបញ្ជា ដើម្បីផ្តល់ទិន្នន័យជាប្រចាំបន្តបន្ទាប់គ្នា និងភ្ជាប់គមនាគមន៍ពីអនុស្ថានីយនីមួយៗ ទៅមជ្ឈមណ្ឌលបញ្ជា ។

**៣-ការគោរពតាមការណែនាំរបស់មជ្ឈមណ្ឌលបញ្ជា –** អ្នកកាន់អាជ្ញាប័ណ្ណត្រូវអនុវត្តតាមការណែនាំរបស់មជ្ឈមណ្ឌលបញ្ជា សម្រាប់ដំណើរការមធ្យោបាយ និងការធ្វើផែនការកាត់ផ្តាច់ចរន្ត ។

**៤-កាតព្វកិច្ចផ្តល់ការតភ្ជាប់ជាមួយមធ្យោបាយរបស់ខ្លួន –** ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រព័ន្ធទាមទារឱ្យមានការភ្ជាប់បន្ថែមនូវប្រព័ន្ធផលិតកម្ម ខ្សែបញ្ជូន ខ្សែបណ្តាញបញ្ជូនរង និងបរិក្ខារអគ្គិសនីរបស់អ្នកប្រើប្រាស់ថ្មីៗ ថែមទៀតជាបន្តបន្ទាប់ ។ នៅក្នុងប្រព័ន្ធដែលកំពុងមានការវិវត្តន៍យ៉ាងលឿនដូចប្រទេសកម្ពុជា ខ្សែបណ្តាញថ្មីនានានឹងត្រូវភ្ជាប់ជាមួយប្រព័ន្ធដែលមានស្រាប់ ដើម្បីពង្រីកប្រព័ន្ធបណ្តាញ និងផ្តល់នូវសេវាថ្មីៗជាបន្តបន្ទាប់ ឱ្យបានកាន់តែច្រើនតំបន់ថែមទៀត ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ ដែលយ៉ាងហោចណាស់នៅក្នុងដំណាក់កាលដំបូង អនុស្ថានីយនីមួយៗ (ទាំងទីធ្លានិងបន្ទប់បញ្ជា) ត្រូវតែមានរក្សាទុកកន្លែងទំនេរ សម្រាប់ការពង្រីកនិងការតភ្ជាប់នៅពេលអនាគត ។ ដូច្នេះ ល័ក្ខខ័ណ្ឌអាជ្ញាប័ណ្ណត្រូវកំណត់ឱ្យបានច្បាស់លាស់អំពីការរក្សាទុកកន្លែងទំនេរ (យ៉ាងហោចណាស់ ពីរ) ក្នុងអនុស្ថានីយ៍នីមួយៗ សម្រាប់ការតភ្ជាប់ទ្វារចរន្តនៅពេល អនាគតក្នុងកម្រិតតង់ស្យុងដំណើរការនីមួយៗ ។ ច្រកចេញនេះ មិនត្រូវការបំពាក់សម្ភារៈឡើយ រហូតដល់ពេលគេត្រូវការវា ប៉ុន្តែ គ្រាន់តែតម្រូវឱ្យទុកកន្លែងទំនេរ ដើម្បីតម្លើងបរិក្ខា និងទូរបញ្ជានៅថ្ងៃក្រោយប៉ុណ្ណោះ ។

**៥-ការតម្លើងនាឡិកាស្ទង់ –** នាឡិកាស្ទង់ដែលមានកម្រិតភាពលំអៀងជាក់លាក់ នឹងត្រូវតម្លើងនៅចំណុចតភ្ជាប់នីមួយៗ ដើម្បីកត់ត្រាបរិមាណថាមពលនាំចូល និងនាំចេញ ដើម្បីកត់ត្រាបរិមាណថាមពលអគ្គិសនី និងបរិមាណផ្សេងទៀត សម្រាប់គោលបំណងពាណិជ្ជកម្ម ។

**៦-ការបើកចំហសិទ្ធិប្រើប្រាស់ –** នៅក្នុងប្រព័ន្ធដែលមានការអភិវឌ្ឍន៍ ការបើកចំហសិទ្ធិប្រើប្រាស់គឺជាការកំណត់របស់ច្បាប់ ។ សម្រាប់ប្រព័ន្ធដូចនៅប្រទេសកម្ពុជា ជាពិសេសសម្រាប់មធ្យោបាយអគ្គិសនីក្រោមអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ទាមទារឱ្យមានការត្រួតពិនិត្យករណីនេះឱ្យបានម៉ត់ចត់ ។ នៅប្រទេសកម្ពុជា សហគ្រិនក្នុងវិស័យឯកជនត្រូវសាងសង់មធ្យោបាយបញ្ជូន

ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងបញ្ជូនអគ្គិសនីជាក់លាក់ ដែលភាគីហត្ថលេខីអាចប្រើមធ្យោបាយធ្វើសេវាកម្មនោះ រហូតដល់អនុភាពទាំងមូលរបស់វា ។ ក្នុងករណីដូច្នេះ អ្នកកាន់អាជ្ញាប័ណ្ណអាចពុំមានសិទ្ធិក្នុងការផ្តល់សិទ្ធិប្រើប្រាស់ដល់បុគ្គលផ្សេងទៀត ។ ដូច្នេះ ដើម្បីអនុញ្ញាតឱ្យមានការបើកចំហឱ្យបុគ្គលផ្សេងទៀត អាចប្រើប្រាស់អានុភាពបំរុងដែលមាននៅសល់ក្នុងបណ្តាញ កិច្ចព្រមព្រៀងបញ្ជូនអគ្គិសនីត្រូវមានល័ក្ខខ័ណ្ឌដែលបើកលទ្ធភាពឱ្យមានកិច្ចសន្យាពាណិជ្ជកម្មសមរម្យ ដើម្បីអនុញ្ញាតឱ្យបុគ្គលផ្សេងទៀតមានសិទ្ធិប្រើប្រាស់មធ្យោបាយធ្វើសេវាកម្មនោះ ។ ប្រសិនបើ អ្នកប្រើប្រាស់មធ្យោបាយធ្វើសេវាកម្មនោះ ជាអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី ពេលនោះ គេអាចផ្តល់សេវាកម្មបញ្ជូន ទោះបីជាមធ្យោបាយធ្វើសេវាកម្មជារបស់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសក៏ដោយ ។ ទោះជាយ៉ាងណាក៏ដោយ ការអនុញ្ញាតឱ្យមានសិទ្ធិប្រើប្រាស់ជាចំហរចំពោះមធ្យោបាយធ្វើសេវាកម្មនេះ សម្រាប់ការប្រើប្រាស់ទូទៅ គឺពុំមានអ្វីជាបញ្ហាចោទឡើយ ។

**៧-ការសម្របសម្រួលលើការការពារប្រព័ន្ធ** - អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែផ្តល់នូវការការពារសម្រាប់មធ្យោបាយបញ្ជូននេះ និងត្រូវក្រិតចំណុចដំណើរការនៃប្រព័ន្ធការពារទៅតាមនីតិវិធីទាំងឡាយដែលអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធ្វើឱ្យមានការសម្របសម្រួលដ៏សមស្របមួយ ក្នុងការកាត់ផ្តាច់ផ្នែកដែលខូចឱ្យបានលឿន និងមានប្រសិទ្ធភាព ។

**៨-គោរពតាមកូដចែកចាយ** - ប្រព័ន្ធបញ្ជូន និងប្រព័ន្ធបញ្ជូនរង នឹងត្រូវភ្ជាប់ជាមួយប្រព័ន្ធចែកចាយ ។ ដូច្នេះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែគោរពតាមកូដចែកចាយ ។

**៩-ជម្រើសក្នុងការទិញយកដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី -** អ្នកគាំទ្ររបស់អ្នកដំណើរការខ្សែបញ្ជូនទោល អាចមានបំណងចង់បានល័ក្ខខ័ណ្ឌទិញយកមធ្យោបាយធ្វើសេវាកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនី បន្ទាប់ពីមធ្យោបាយធ្វើសេវាកម្មនោះ បានភ្ជាប់ទៅបណ្តាញជាតិ និងក្រោយពីបានដំណើរការតាមចំនួនឆ្នាំមួយកំណត់ ។ ល័ក្ខខ័ណ្ឌនេះអាចធ្វើឱ្យអ្នកវិនិយោគឯកជនលើមធ្យោបាយបញ្ជូន មានការរួញរា ហើយអាចពន្យារការពង្រីកបណ្តាញ ។ ល័ក្ខខ័ណ្ឌអាជ្ញាប័ណ្ណសម្រាប់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស អាចមិនបានចែងអំពីការមិនបានផ្ទេរមធ្យោបាយបញ្ជូនទៅឱ្យអ្នកកាន់អាជ្ញាប័ណ្ណជាតិបញ្ជូនអគ្គិសនី ។ ទោះជាយ៉ាងណាក៏ដោយ អ្នកកាន់អាជ្ញាប័ណ្ណជាតិបញ្ជូនអគ្គិសនីមានសិទ្ធិទំនាក់ទំនងជាមួយអ្នកវិនិយោគឯកជន ដើម្បីសាងសង់មធ្យោបាយបញ្ជូនលើមូលដ្ឋាននៃការវិនិយោគរូបភាព BOT ឬ កំណត់ល័ក្ខខ័ណ្ឌសម្រាប់ទិញមធ្យោបាយបញ្ជូនយក បន្ទាប់ពីបានដំណើរការមធ្យោបាយបញ្ជូននោះ មួយរយៈពេលមក ។

## ដ-អាជ្ញាប័ណ្ណសម្រាប់ដំណើរការបណ្ដាញបញ្ជូនតង់ស្យុងខ្ពស់

បញ្ហាដែលពាក់ព័ន្ធជាមួយការផ្ដល់អាជ្ញាប័ណ្ណឱ្យបុគ្គលណាមួយ ដែលអាចសាងសង់ខ្សែបណ្ដាញបញ្ជូនតង់ស្យុងខ្ពស់ដូចបានអធិប្បាយនៅក្នុងចំណុច "ថ" មានដូចខាងក្រោម :

១-អគ្គិសនីកម្ពុជា : អគ្គិសនីកម្ពុជាគឺជាក្រុមហ៊ុនរដ្ឋមួយដែលបានទទួលអាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនី និងមានសិទ្ធិធ្វើសេវាកម្មបញ្ជូនអគ្គិសនីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ អគ្គិសនីកម្ពុជាអាចដំណើរការខ្សែបណ្ដាញបញ្ជូនថ្មីៗទាំងឡាយ ក្នុងក្របខ័ណ្ឌអាជ្ញាប័ណ្ណដែលអគ្គិសនីកម្ពុជាកំពុងមាន ។

២-រោងចក្រអគ្គិសនីថ្មី : ខ្សែបណ្ដាញតង់ស្យុងខ្ពស់ដែលមានប្រវែងខ្លី (ប្រវែងរហូតដល់ ៥០ គម) ហើយប្រើប្រាស់សម្រាប់តែការតភ្ជាប់រោងចក្រអគ្គិសនីនេះ ជាមួយប្រព័ន្ធបញ្ជូន អាចត្រូវបានចាត់ទុកថាជាហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់និងជាផ្នែកមួយនៃរោងចក្រអគ្គិសនី ។ ដូច្នេះ វាអាចបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណផលិតកម្ម ដែលចេញឱ្យសម្រាប់ដំណើរការរោងចក្រអគ្គិសនីបាន ។ សម្រាប់ដំណើរការខ្សែបណ្ដាញដែលមានប្រវែងលើសពីនេះ ជាចាំបាច់គឺត្រូវមានអាជ្ញាប័ណ្ណបញ្ជូន ។ ដូច្នេះ អ្នកកាន់អាជ្ញាប័ណ្ណត្រូវមានអាជ្ញាប័ណ្ណរួមមួយ ដែលរួមមានអាជ្ញាប័ណ្ណផលិតកម្ម និងអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ឬ មួយក៏ត្រូវផ្ទេរខ្សែតង់ស្យុងខ្ពស់នេះឱ្យទៅអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ។

៣-ឧស្សាហកម្មឬអ្នកប្រើប្រាស់ធុនធំ : ខ្សែបណ្ដាញតង់ស្យុងខ្ពស់ដែលមានប្រវែងខ្លី (ប្រវែងរហូតដល់ ៣០ គម) ហើយប្រើប្រាស់សម្រាប់តែការនាំថាមពលអគ្គិសនីទៅកន្លែងប្រើប្រាស់ផ្ទាល់ខ្លួន ខ្សែបណ្ដាញតង់ស្យុងខ្ពស់នោះ អាចត្រូវបានចាត់ទុកថាជាហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងជាផ្នែកមួយនៃបរិក្ខាអគ្គិសនីរបស់អ្នកប្រើប្រាស់ ហើយមិនចាំបាច់មានអាជ្ញាប័ណ្ណសម្រាប់ដំណើរការខ្សែបណ្ដាញតង់ស្យុងខ្ពស់នោះទេ ។ ចំពោះខ្សែបណ្ដាញដែលមានប្រវែងលើសពីនេះ ហើយប្រសិនបើ ខ្សែបណ្ដាញតង់ស្យុងខ្ពស់នោះត្រូវបានប្រើប្រាស់ដើម្បីធ្វើសេវាកម្មផ្សេងទៀត នោះអ្នកប្រើប្រាស់ ឬ ឧស្សាហកម្មធុនធំត្រូវមានអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ឬមួយក៏ត្រូវផ្ទេរខ្សែតង់ស្យុងខ្ពស់នេះទៅឱ្យអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ។

៤-អ្នកធ្វើសេវាកម្មបញ្ជូនអគ្គិសនី : អ្នកធ្វើសេវាកម្មបញ្ជូនអគ្គិសនីអាចដំណើរការខ្សែបញ្ជូននេះ ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។

៥-អ្នកធ្វើសេវាកម្មបញ្ជូនអគ្គិសនីសម្រាប់ប្រទេសច្រើន : អ្នកធ្វើសេវាកម្មបញ្ជូនអគ្គិសនីប្រភេទនេះ អាចដំណើរការខ្សែបញ្ជូន ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។

ក្នុងករណីខាងលើ (លើកលែងចំណុចទី៥) អ្នកធ្វើសេវាកម្មអាចមានអាជ្ញាប័ណ្ណធ្វើសេវាកម្មបន្តជំនួសឱ្យអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស អនុលោមទៅតាមមាត្រា ៤០ របស់ច្បាប់ស្ដីពីអគ្គិសនី ។ សម្រាប់គោលបំណងនេះ អ្នកធ្វើសេវាកម្មត្រូវចុះកិច្ចព្រមព្រៀងធ្វើសេវាកម្មបន្តជាមួយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនី ឬជាមួយនឹងអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស (ផ្ដល់អាជ្ញាប័ណ្ណសម្រាប់ដំណើរការបណ្ដាញបញ្ជូនដែលបានរៀបរាប់ខាងលើ) ។

## ៥.អាជ្ញាប័ណ្ណសម្រាប់ដំណើរការបណ្តាញបញ្ជូនរង

ខ្សែបណ្តាញតង់ស្យុងមធ្យមអាចជាផ្នែកមួយនៃប្រព័ន្ធចែកចាយឬប្រព័ន្ធបញ្ជូនរង ។ ករណីនេះអាចមានច្រើននៅក្នុងពេលដែលប្រព័ន្ធបណ្តាញកំពុងតែវិវត្តន៍ដូចជានៅប្រទេសកម្ពុជាយើងនេះ ។ នៅក្នុងសេចក្តីសម្រេចមុន អាជ្ញាធរអគ្គិសនីកម្ពុជាបានសម្រេចថា "ខ្សែបណ្តាញតង់ស្យុងមធ្យមនិងទាបរបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយមួយនៅក្នុងតំបន់ចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណនោះ ដែលប្រើប្រាស់សម្រាប់ផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ត្រូវចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធបណ្តាញចែកចាយ" ។ អាជ្ញាប័ណ្ណសម្រាប់ខ្សែបណ្តាញតង់ស្យុងមធ្យមដែលពុំមានចែងនៅក្នុងអាជ្ញាប័ណ្ណចែកចាយ និងដែលលើកឡើងនៅក្នុងចំណុច "ឆ" មានលក្ខណៈដូចខាងក្រោម :

១-អគ្គិសនីកម្ពុជា : ហេដ្ឋារចនាសម្ព័ន្ធតង់ស្យុងមធ្យមរបស់អគ្គិសនីកម្ពុជាដែលឋិតនៅក្រៅតំបន់ចែកចាយរបស់ខ្លួន ហើយដែលប្រើប្រាស់សម្រាប់ផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ផ្សេងទៀត ឬអ្នកប្រើប្រាស់ធុនធំ អាចដំណើរការនៅក្នុងក្របខ័ណ្ឌអាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្តាញជាតិបញ្ជូនអគ្គិសនីដែលបានចេញឱ្យអគ្គិសនីកម្ពុជារួចហើយ ។

២-រោងចក្រអគ្គិសនីថ្មី : ខ្សែបណ្តាញតង់ស្យុងមធ្យមប្រវែងខ្លី (ប្រវែងរហូតដល់ ២០ គម) ដែលប្រើប្រាស់សម្រាប់តែធ្វើការតភ្ជាប់រោងចក្រអគ្គិសនីនោះជាមួយប្រព័ន្ធតង់ស្យុងមធ្យម អាចចាត់ទុកជាហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងជាផ្នែកមួយនៃរោងចក្រអគ្គិសនី ។ ដូច្នេះ គឺអាចដំណើរការក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណផលិតកម្ម ដែលបានផ្តល់ជូនសម្រាប់ដំណើរការរោងចក្រអគ្គិសនីនោះ ។ សម្រាប់ដំណើរការខ្សែបណ្តាញដែលមានប្រវែងលើសពីនេះ ជាចាំបាច់គឺត្រូវមានអាជ្ញាប័ណ្ណបញ្ជូន ។ ដូច្នេះ គេគួរទទួលបានអាជ្ញាប័ណ្ណរួមមួយ ដែលរួមមានអាជ្ញាប័ណ្ណផលិតកម្ម និងអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ឬមួយក៏ត្រូវផ្ទេរខ្សែតង់ស្យុងខ្ពស់នេះឱ្យទៅអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ។

៣-រោងចក្រឧស្សាហកម្មឬអ្នកប្រើប្រាស់ធុនធំ : ខ្សែបណ្តាញតង់ស្យុងមធ្យមដែលមានប្រវែងខ្លី (ប្រវែងរហូតដល់ ១០ គម) ហើយប្រើប្រាស់សម្រាប់តែការផ្តល់ថាមពលអគ្គិសនីទៅកន្លែងប្រើប្រាស់ផ្ទាល់ខ្លួន ខ្សែបណ្តាញតង់ស្យុងមធ្យមនោះ អាចត្រូវបានចាត់ទុកថាជាហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងជាផ្នែកមួយនៃបរិក្ខាអគ្គិសនីរបស់អ្នកប្រើប្រាស់ ហើយមិនចាំបាច់មានអាជ្ញាប័ណ្ណសម្រាប់ដំណើរការខ្សែបណ្តាញតង់ស្យុងមធ្យមនោះទេ ។ ចំពោះខ្សែបណ្តាញដែលមានប្រវែងលើសពីនេះ ហើយប្រសិនបើខ្សែបណ្តាញនោះត្រូវបានប្រើប្រាស់ដើម្បីធ្វើសេវាកម្មផ្សេងទៀត នោះអ្នកប្រើប្រាស់ឬឧស្សាហកម្មធុនធំត្រូវមានអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ឬមួយក៏ត្រូវផ្ទេរខ្សែតង់ស្យុងមធ្យម នេះទៅឱ្យអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូន ឬអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនៅតំបន់នោះ ។

៤-អ្នកកាន់អាជ្ញាប័ណ្ណចែកចាយ : ខ្សែបណ្ដាញតង់ស្យុងមធ្យមរបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយមួយ ដែលឋិតនៅក្រៅតំបន់ចែកចាយរបស់ខ្លួន ដែលប្រើប្រាស់សម្រាប់នាំចូលអគ្គិសនីមកផ្គត់ផ្គង់ឱ្យអ្នកប្រើប្រាស់ក្នុងតំបន់ចែកចាយរបស់ខ្លួន អាចដំណើរការនៅក្នុងក្របខ័ណ្ឌអាជ្ញាប័ណ្ណចែកចាយដែលមានលក្ខខ័ណ្ឌដោយឡែក ។ អ្នកកាន់អាជ្ញាប័ណ្ណអាចធ្វើជាម្ចាស់និងដំណើរការហេដ្ឋារចនាសម្ព័ន្ធតង់ស្យុងមធ្យមដែលឋិតនៅក្រៅតំបន់ចែកចាយរបស់ខ្លួន ។ ប៉ុន្តែ ប្រសិនបើហេដ្ឋារចនាសម្ព័ន្ធតង់ស្យុងមធ្យមនេះត្រូវបានប្រើប្រាស់សម្រាប់ផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀតដែរ នោះ អ្នកកាន់អាជ្ញាប័ណ្ណចែកចាយនោះត្រូវមានអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។

៥-អ្នកធ្វើសេវាកម្មឯករាជ : អ្នកធ្វើសេវាកម្មឯករាជដែលជាម្ចាស់ហេដ្ឋារចនាសម្ព័ន្ធតង់ស្យុងមធ្យមប្រើសម្រាប់ផ្ទេរអគ្គិសនីឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ឬឱ្យអ្នកប្រើប្រាស់ ត្រូវតែមានអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។

ដូចបានជម្រាបជូននៅក្នុងចំណុច “ឈ” អ្នកធ្វើសេវាកម្មអាចមានអាជ្ញាប័ណ្ណធ្វើសេវាកម្មបន្តជំនួសឱ្យអាជ្ញាប័ណ្ណបញ្ជូនសម្រាប់គោលបំណងពិសេស ។

## ឌ-អាជ្ញាប័ណ្ណសម្រាប់ដំណើរការមជ្ឈមណ្ឌលបញ្ជា

យោងតាមការកំណត់ក្នុងមាត្រា ៣៦ របស់ច្បាប់ស្ដីពីអគ្គិសនី អាជ្ញាធរអគ្គិសនីកម្ពុជា អាចចេញអាជ្ញាប័ណ្ណបែងចែកឱ្យបុគ្គលណាមួយ លុះត្រាតែប្រព័ន្ធបញ្ជូនអគ្គិសនីគ្របដណ្ដប់លើតំបន់សំខាន់ៗច្រើន សេវាកម្មផលិតកម្ម សេវាកម្មបញ្ជូន និងសេវាកម្មចែកចាយ បានត្រូវបំបែកចេញពីគ្នាជាអាជីវកម្មដោយឡែករួចរាល់ ។ ដើម្បីអនុវត្តឱ្យបានពេញលេញនូវល័ក្ខខ័ណ្ឌខាងលើនេះ គេត្រូវការរយៈពេលច្រើនឆ្នាំបន្តទៀត ។ ដូច្នេះ រហូតដល់ពេលនោះ សេវាកម្មបែងចែកមិនអាចបំបែកចេញពីសេវាកម្មបញ្ជូនបានឡើយ ។ សេវាកម្មបែងចែកនេះត្រូវតែផ្តល់ដោយអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនសម្រាប់បណ្ដាញជាតិបញ្ជូនអគ្គិសនី ដែលបច្ចុប្បន្ននេះគឺជាអ្នកកាន់អាជ្ញាប័ណ្ណបញ្ជូនតែម្នាក់គត់ និងដែលសង្ឃឹមថា នឹងបន្តធ្វើជាម្ចាស់និងគ្រប់គ្រងមួយភាគធំនៃប្រព័ន្ធបញ្ជូនអគ្គិសនី (តាមការកំណត់នៅក្នុងកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ឬកិច្ចព្រមព្រៀងបញ្ជូន) ។

**មាត្រា ៣៦.-**

អ្នកកាន់អាជ្ញាប័ណ្ណបែងចែកអគ្គិសនីមានសិទ្ធិចាត់ចែង គ្រប់គ្រង និងធ្វើប្រតិបត្តិការលើមធ្យោបាយបែងចែកអគ្គិសនី ដើម្បីសម្របសម្រួលការប្រគល់និងការទទួលអគ្គិសនីនៃប្រព័ន្ធផលិតកម្ម ប្រព័ន្ធបញ្ជូននិងប្រព័ន្ធចែកចាយ ។

អាជ្ញាប័ណ្ណបែងចែកអគ្គិសនីត្រូវបញ្ញត្តិអំពីល័ក្ខខ័ណ្ឌដើម្បីរក្សាកិច្ចដំណើរការនៃប្រព័ន្ធផលិតកម្មអគ្គិសនី ប្រព័ន្ធបញ្ជូននិងប្រព័ន្ធចែកចាយដែលស្ថិតក្នុងរង្វង់សមត្ថកិច្ចបែងចែករបស់ខ្លួន ឱ្យមានសុវត្ថិភាព ស្ថេរភាពនិងប្រសិទ្ធភាព ។

អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញអាជ្ញាប័ណ្ណបែងចែកអគ្គិសនីឱ្យបុគ្គលណាមួយ សម្រាប់ធ្វើសេវាកម្មបែងចែកអគ្គិសនីលើប្រព័ន្ធអគ្គិសនីមួយបាន លុះត្រាតែ :

១- ប្រព័ន្ធអគ្គិសនីនោះមានបណ្តាញបញ្ជូនតភ្ជាប់តំបន់ចែកចាយសំខាន់ៗច្រើន

២- សេវាកម្មផលិតកម្ម សេវាកម្មបញ្ជូននិងសេវាកម្មចែកចាយ បានត្រូវបំបែកចេញពីគ្នារួចរាល់ និង

៣- សេវាកម្មបែងចែកអគ្គិសនីមានទំហំធំគ្រប់គ្រាន់ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាយល់ថា អាចឱ្យធ្វើសេវាកម្មដោយឡែកបាន ។

អាជ្ញាប័ណ្ណដែលបានចេញស្របតាមមាត្រានេះអាចមានអាណត្តិមួយមិនកំណត់ និងអាចដកហូតវិញបានស្របតាមច្បាប់នេះ ។